ក

មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

០២-១២-២០០៦ -ព្រះរាជក្រម នស/រកម/១២០៦/០២៨ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ១ ទី ២ ទី ៤ ទី ៧ ទី ៩ ទី ១១ ទី ១២ ទី ១៣អា ទី ១៣បេ ទី ១៥ ទី ១៦ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាងនិងក្នុង រង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្របសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ***(ត មកពីរាជកិច្ចលេខ ៩១)*** ៨០៧១

២~ព្រះរាជក្រឹត្យ

០៩-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៨៣ ស្តីពីការបញ្ចប់មុខតំណែងឯកឧត្តម **សុខ ចមឆាន់ឫទ្ធី** ពីជំនួយការឯកឧត្តម **លី ឡាយស្រេង** ឧបនាយករដ្ឋមន្ត្រី និងត្រូវបានតែងតាំងឯកឧត្តម **សួខ សុខេន** មានឋានៈស្មើអគ្គនាយក ជំនួសវិញ ៨១២៨

០៩-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៨៤ ស្តីពីការតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់របស់ក្រសួងសុខាភិបាល គិតចាប់ពីថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០០៦ នេះតទៅ នូវមន្ត្រីរាជការស៊ីវិលចំនួន ៣៦ រូប ៨១២៩

០៩-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៨៥ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **គឹម ឆា** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ៨១៣២

II~គ្រុមប្រឹក្សាធម្មនុញ្ញ

១៣-១២-២០០៦-សេចក្តីសម្រេចលេខ ០៨៩/០១៦/២០០៦ កបធ.ច ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦ ៨១៣៣

III~រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៤-១២-២០០៦ -អនុក្រឹត្យលេខ ១៤៥ អនក្រ.បក ស្តីពីការបង្កើតមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម ៨១៣៦

១៤-១២-២០០៦ -អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨១៣៨

១៥-១២-២០០៦ -អនុក្រឹត្យលេខ ១៤៧ អនក្រ.បក ស្ដីពីការលុបឋានានុក្រមអភិបាលរងទី ១ ខេត្ត ក្រុង ៨១៤០

១៣-១២-២០០៦ -អនុក្រឹត្យលេខ ៧៦៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៨១៤២

១៣-១២-២០០៦ -អនុក្រឹត្យលេខ ៧៦៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៨១៤៣

១៣-១២-២០០៦ -អនុក្រឹត្យលេខ ៧៦៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៨១៤៤

១៣-១២-២០០៦ -អនុក្រឹត្យលេខ ៧៧០ អនក្រ.តត ស្ដីពីការផ្លាស់ប្ដូរ និងបន្ថែមសមាសភាព អង្គភាពប្រឆាំងអំពើពុករលួយ ៨១៤៥

១៣-១២-២០០៦ -អនុក្រឹត្យលេខ ៧៧១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៨១៤៦

១៥-១២-២០០៦ -អនុក្រឹត្យលេខ ៧៧២ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨១៤៧

១៥-១២-២០០៦ -អនុក្រឹត្យលេខ ៧៧៣ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៨១៤៨

១៥-១២-២០០៦ -អនុក្រឹត្យលេខ ៧៧៤ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ៨១៤៩

១៥-១២-២០០៦ -អនុក្រឹត្យលេខ ៧៧៥ អនក្រ.តត ស្ដីពីការតម្លើងថ្នាក់មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្នុងឋានន្តរស័ក្តិវរមន្ត្រី ៨១៥១

IV_ការងារបណ្ដាក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

០៦-១២-២០០៦ -ប្រកាសលេខ ២៣០១ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ " **បណ្ដុះវិជ្ជា** " ស្ថិតនៅក្នុងឃុំ ស្វាយភ្លើង ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ៨១៥២

០៦-១២-២០០៦ -ប្រកាសលេខ ២៣០២ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ " **ហ៊ុន សែន ទីរង** " ស្ថិតនៅ ក្នុងឃុំ ទីរង ស្រុក សណ្ដាន់ ខេត្ត កំពង់ធំ ៨១៥៣

០៦-១២-២០០៦ -ប្រកាសលេខ ២៣០៣ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ " **កំពង់ឫស្សី** " ស្ថិតនៅ ក្នុងឃុំ ជីរោ ទី ១ ស្រុក ត្បូងឃ្មុំ ខេត្ត កំពង់ចាម ៨១៥៤

០៦-១២-២០០៦ -ប្រកាសលេខ ២៣០៤ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ " **ស្រែអណ្ដូង** " ស្ថិតនៅ ក្នុងឃុំ សំឡូត ស្រុក សំឡូត ខេត្ត បាត់ដំបង ៨១៥៥

០៦-១២-២០០៦ -ប្រកាសលេខ ២៣០៥ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ " **គីរីសិលាកែវ** " ស្ថិតនៅក្នុងឃុំ តាគ្រាម ស្រុក បាណន់ ខេត្ត បាត់ដំបង ៨១៥៦

០៦-១២-២០០៦ -ប្រកាសលេខ ២៣០៦ អយក.ប្រក ស្ដីពីការពង្រីក និងប្ដូរឈ្មោះអនុវិទ្យាល័យ " **ភ្នំព្រឹក** " ទៅជាវិទ្យាល័យ " **ពេជ្រចិន្តា** " ស្ថិត នៅក្នុងឃុំ ពេជ្រចិន្តា ស្រុក ភ្នំព្រឹក ខេត្ត បាត់ដំបង ៨១៥៧

០៦-១២-២០០៦ -ប្រកាសលេខ ២៣០៧ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះវិទ្យាល័យ " **សំរោងអណ្ដែត** " ទៅជាវិទ្យាល័យ " **សម្ដេច ហ៊ុន សែន ភ្នំពេញថ្មី** " ស្ថិត នៅក្នុងសង្កាត់ ភ្នំពេញថ្មី ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ៨១៥៨

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១១-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាហ្សាលីយ៉ា** ៨១៥៩

១២-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.អេច.ឌី (ខេមបូឌា) ហាយវ៉េ ផៅវ័រ ឌីវេឡុបមេន** ៨១៦១

១២-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខ្មែរ អ៊ិនណូវេសិន** ៨១៦៣

១២-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ ណាយ ម៉ាឃីន** ៨១៦៥

១២-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចំរុង_ផល្លា (ខេមបូឌា)** ៨១៦៧

១២-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.ឃី.ម៉ាក់** ៨១៦៩

១២-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច អេស ធី ឌី ស៊ីមតិច** ៨១៧១

១២-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦១៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្លូប៊ល អ៊ិនធើណេសិនណល (ខេមបូឌា)** ៨១៧៣

១៣-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើរ៉េក សូលូសិន ខូ អិលធីឌី** ៨១៧៥

១៦-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមខូ ផាតនើរ លីមីធីត** ៨១៧៧

១៧-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃុន សៀ ឌីវេឡុបមេន គ្រុប** ៨១៧៩

១៧-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទី.អេច.អេច.ឃ្វាម៉ា ខូ អិលធីឌី** ៨១៨១

១៧-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថៃ លី គ្រេឌីង** ៨១៨៣

ឃ

១៧-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦២៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចឺ អេស អិល** ៨១៨៥

១៧-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៣១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ែស៊ីន_ទ៊ាឡូ ម្លាមិន អ៊ិនធើណេ សិនណល** ៨១៨៧

ព្រះរាជក្រម

នស/រកម/១២០៦/០២៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា១៧ និងពិធីសារទី១ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសាធារណរដ្ឋប្រជាមានិតចិន សាធា-

រណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញនិងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ១ ទី ២ ទី ៤ ទី ៧ ទី ៩ ទី ១១ ទី ១២ ទី ១៣អា ទី ១៣បេ ទី ១៥ ទី ១៦ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាងនិងក្នុង រវាងរដ្ឋាភិបាលនៃព្រះរាជាណា-ចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យ-ប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការសម្រួល ការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

មាត្រា ១.-

អនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ២ ទី ៤ ទី ៧ ទី ១១ ទី ១២ ទី ១៣អា ទី ១៥ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ ដែលធ្វើនៅទីក្រុងភ្នំពេញ នាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ និងឧបសម្ព័ន្ធទី ១ ទី ៩ ទី ១៣បេ ទី ១៦ ដែលធ្វើនៅទីក្រុងវៀងច័ន្ទ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាងនិងក្នុង រដ្ឋរដ្ឋាភិបាលនៃព្រះរាជាណា-ចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តឧបសម្ព័ន្ធពិធីសារ និងវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ពរល.០៦១២.៥០១

ហត្ថលេខា និងព្រះរាជលញ្ជករ

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ហត្ថលេខា

ស៊ុន ចាន់ថុល

លេខ : ៤៥០ ធ.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជីនកេង

(ត មកពីរាជកិច្ចលេខ ៥១)

ឧបសម្ព័ន្ធទី ៧
បទប្បញ្ញត្តិចរាចរណ៍តាមផ្លូវថ្នល់ និងផ្លាកសញ្ញា

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន
(តទៅហៅកាតថា " ឧបសម្ព័ន្ធ ")

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (តទៅហៅកាត់ថា" ភាគីចុះកិច្ចសន្យា")

ដោយយោងទៅផល់ កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដជប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាតំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាងហ្គូន ; ដែលបានយល់ព្រមចូល ដោយព្រះរាជាណាចក្រកម្ពុជា នៅយ៉ាងហ្គូន នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ បានយល់ព្រមចូល ដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី តទៅហៅកាត់ថា" កិច្ចព្រមព្រៀង"

ដោយយោងទៅផល់មាត្រាទី ៣(បេ)និង(អិន) នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា

ដោយយោងទៅផល់ មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង ។

ដោយយោងទៅផល់ កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានិលឡា ក្នុងខែមករា ឆ្នាំ ២០០០, កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទិ១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់ បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្ហើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសាររបស់វា ក្នុងឆ្នាំ ២០០៥

ដោយយោងទៅផល់ មាត្រាទី ១៥ និង ២៦ នៃកិច្ចព្រមព្រាងដែលបានស្នើអោយឧបសម្ព័ន្ធនេះ ធ្វើការលំអិតផ្នែកបច្ចេកទេស ។

បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រា ១.~ បទប្បញ្ញត្តិចរាចរផ្លូវគោក

បទប្បញ្ញត្តិចរាចរតាមផ្លូវគោក គឺជាបទបញ្ជានៅតាមផ្លូវថ្នល់ ដូចដែលបានបញ្ញត្តិនៅក្នុងឯកសារភ្ជាប់ ឬឧបទាន ទី ១ នៃឧបសម្ព័ន្ធនេះ ។

មាត្រា ២.~ ភ្លើងសញ្ញា និងផ្លាកសញ្ញាតាមផ្លូវថ្នល់

ក- ផ្លាកសញ្ញា ភ្លើងសញ្ញា និមិត្តសញ្ញា និងគំនូសសញ្ញាតាមផ្លូវថ្នល់ទាំងឡាយ នៅតាមដងផ្លូវនានា និងផ្លូវបៀង មួយចំនួន ត្រូវបានកំណត់ក្នុងពិធីសារទី ១ នៃកិច្ចព្រមព្រៀង ត្រូវបានបញ្ញត្តិដូចនៅក្នុងឯកសារភ្ជាប់ ឬឧបទាន ទី ២ នៃឧបសម្ព័ន្ធនេះ ។

ខ- ក្នុងរយៈពេលអន្តរកាល(បណ្តោះអាសន្ន)មួយដែលមានរយៈពេលបួនឆ្នាំ បន្ទាប់ចាប់ពីពេលដែលឧបសម្ព័ន្ធនេះចូលជាធរមាន ក្នុងទឹកដីរបស់ពួកគេ ភាគីចុះកិច្ចសន្យាត្រូវរៀបចំឱ្យទូលំទូលាយ ផ្លាស់ប្តូរ ឬដាក់បន្ថែមនូវផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញានានានៅតាមដងផ្លូវ និងផ្លូវបៀងមេនានា ដែលបានកំណត់ក្នុងពិធីសារទី ១ នៃកិច្ចព្រមព្រៀង ដែលបើទោះបីជាផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា ឬគំនូស សញ្ញាទាំងឡាយនោះ មានលក្ខណៈដូចគ្នាទៅនឹងប្រព័ន្ធផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា ឬគំនូសសញ្ញាទាំងឡាយដែលបញ្ញត្តិដោយឯកសារភ្ជាប់ឬឧបទានទី២នៃឧបសម្ព័ន្ធនេះ ប៉ុន្តែត្រូវបានគេប្រើវានៅក្នុងន័យមួយផ្សេងក្រៅ ពីអត្ថន័យដែលបានកំណត់ក្នុងឯកសារភ្ជាប់ ឬឧបទានទី ២ នេះក៏ដោយ ។

គ- ក្នុងរយៈពេលអន្តរកាល(បណ្តោះអាសន្ន)មួយដែលមានរយៈពេល១៥ឆ្នាំ បន្ទាប់ចាប់ពីពេលដែលឧបសម្ព័ន្ធនេះចូលជាធរមាន ក្នុងទឹកដីរបស់ពួកគេ ភាគីចុះកិច្ចសន្យាត្រូវរៀបចំឱ្យទូលំទូលាយ ផ្លាស់ប្តូរ ឬដាក់បន្ថែមនូវផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញានានានៅតាមដងផ្លូវ និងផ្លូវបៀងនានា ដែលបានកំណត់ក្នុងពិធីសារទី ១ នៃកិច្ចព្រមព្រៀងដែលផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញាដើមទាំងអស់នោះ មិនមានន័យស្របគ្នាជាគោលការណ៍ទៅនឹងប្រព័ន្ធផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញា ឬមិនមានបញ្ញត្តិដោយឯកសារភ្ជាប់ឬឧបទានទី២នៃឧបសម្ព័ន្ធនេះ ។នៅក្នុងរយៈពេលនេះដើម្បីអោយអ្នកប្រើប្រាស់ផ្លូវថ្នល់មានការយល់ដឹងអំពីប្រព័ន្ធផ្លាកដែលបានបញ្ញត្តិដោយឯកសារភ្ជាប់ ឬឧបទានទី២នោះ ផ្លាកសញ្ញា និងនិមិត្តសញ្ញាដើមនានា គួតែរក្សាទុកនិងដាក់តំឡើងផ្លាកសញ្ញា និងនិមិត្តសញ្ញាថ្មីទាំងឡាយ ដូចមានបញ្ញត្តិ នៅក្នុងឯកសារភ្ជាប់ ឬឧបទានទី ២ ឱ្យនៅក្បែរ ផ្លាកសញ្ញា និងនិមិត្តសញ្ញាដើមនានាដែលមានស្រាប់ទាំងនោះ ។

ឃ- នៅពេលណាដែលឯកសារភ្ជាប់ឬឧបទានទី២ នៃឧបសម្ព័ន្ធនេះ មិនបានបញ្ញត្តិ នូវផ្លាកសញ្ញា និមិត្តសញ្ញា ឬ គំនូសសញ្ញាណាមួយ ដើម្បីបញ្ជាក់នូវបទបញ្ជា ឬការនាំពត៌មានជាក់លាក់មួយដល់អ្នកប្រើប្រាស់ផ្លូវថ្នល់នានាទេនោះ ភាគីចុះកិច្ចសន្យាត្រូវបានគេអនុញ្ញាតជាចំហ ក្នុងការប្រើប្រាស់សំរាប់គោលបំណងខាងលើនេះ នូវផ្លាកសញ្ញា និមិត្តសញ្ញា ឬគំនូសសញ្ញានានាដែលពួកគេត្រូវការ ដែលត្រូវបញ្ជាក់ថាផ្លាកសញ្ញា និមិត្តសញ្ញា ឬគំនូសសញ្ញាទាំងនោះមិនត្រូវបានគេកំណត់អត្ថន័យដោយឡែកណាមួយ ដោយឯកសារភ្ជាប់ ឬឧបទានទី២ទេ និងបញ្ជាក់ថា ផ្លាកសញ្ញា និមិត្តសញ្ញា ឬគំនូសសញ្ញា ទាំងនោះត្រូវសំរបទៅនឹងប្រព័ន្ធ ដែលបានបញ្ញត្តិដោយឯកសារភ្ជាប់ទី ២ ។

ង- បញ្ញត្តិដែលមានចែងនៅក្នុងឧបសម្ព័ន្ធនេះ មិនបានតំរូវឱ្យភាគីចុះកិច្ចសន្យា អនុម័តទទួលយក ផ្លាកសញ្ញា និងគំនូសសញ្ញាដែលបានបញ្ញត្តិដោយឯកសារភ្ជាប់ ឬឧបទានទី២ទាំងស្រុងនោះទេ ។ ផ្ទុយទៅវិញ ភាគីចុះកិច្ចសន្យាត្រូវកំរិតនូវចំនួន និងប្រភេទនៃផ្លាកសញ្ញា ឬគំនូសសញ្ញា ដែលពួកគេត្រូវអនុម័តយល់ព្រមក្នុងការទទួលយកនូវអ្វីដែលចាំបាច់ខានមិនបាន តែប៉ុណ្ណោះ ។

ច- ភាគីចុះកិច្ចសន្យាធានាក្នុងការហាមឃាត់នៅក្នុងទឹកដីរបស់ពួកគេ ក្នុងការសរសេរ ឬដាក់(តំឡើង)បន្ថែមឧបករណ៍សំភារៈ ក្តារផ្សព្វផ្សាយពាណិជ្ជកម្ម ផ្លាកជូនដំណឹង គំនូសសញ្ញា ឬឧបករណ៍ដ៏ទៃទៀត ឱ្យស្ថិតនៅជិតក្បែរផ្លាកសញ្ញា ឬឧបករណ៍ត្រួតពិនិត្យចរាចរដ៏ទៃទៀត ដែលធ្វើអោយផ្លាកសញ្ញាទាំងនោះមិនអាចសំគាល់បាន និងយល់បានតិចតួច ឬធ្វើអោយយល់ច្រលំប្រថុយប្រថាននឹងគ្រោះថ្នាក់ និងធ្វើអោយវង្វេងស្មារតី ដល់អ្នកប្រើប្រាស់ផ្លូវថ្នល់ ដែលបង្ក និងធ្វើអោយខូចប្រយោជន៍ ដល់សុវត្ថិភាពចរាចរ ។

GMS-Annex7_kh- 01 Sep 2006 1/19/2001

មាត្រា ៣.- ការបញ្ជាក់

ក- ការប្រើប្រាស់ភាសា(អក្សរ)សរសេរ នៅក្នុងគំនូសសញ្ញាផ្លូវថ្នល់ ផ្លាកសញ្ញា និងភ្លើងសញ្ញា អាចនឹងកំណត់ឱ្យនៅត្រឹមចំនួនអប្បរមាមួយ ហើយត្រូវប្រើរូបសញ្ញានានាជំនួសឱ្យបានច្រើនជាងវិញ ។

ខ- ក្នុងការអធិប្បាយផ្លាកសញ្ញា គំនូសសញ្ញាផ្លូវថ្នល់ ដោយការប្រើភាសាអង់គ្លេស/ឡាតាំង លេខអារ៉ាប់នោះមិនមានអត្ថន័យថា បានហាមឃាត់មិនឱ្យមានការប្រើប្រាស់នូវភាសាជាតិ ស្របជាមួយគ្នានោះទេ ។

មាត្រា ៤.- ការធ្វើវិសោធនកម្ម

ភាគីចុះកិច្ចសន្យាណាមួយក៏ដោយ អាចស្នើធ្វើវិសោធនកម្ម លើឧបសម្ព័ន្ធ តាមរយៈគណកម្មាធិការរួម ។ ការធ្វើវិសោធនកម្មនោះ ត្រូវតែជាកម្មវត្ថុនៃការឯកភាពគ្នាជាឯកច្ឆ័ន្ទ ពីភាគីចុះកិច្ចសន្យាទាំងអស់ ។

មាត្រា ៥.- ការផ្តល់សច្ចាប័ន និងការយល់ព្រម

ឧបសម្ព័ន្ធនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រម ពីរដ្ឋាភិបាលទាំងឡាយដែលជាភាគីចុះកិច្ចសន្យា ។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន ។

មាត្រា ៦.- ការចូលជាធរមាន

ឧបសម្ព័ន្ធ នឹងត្រូវចូលជាធរមាន នៅថ្ងៃដែល ០២ភាគីចុះកិច្ចសន្យាយ៉ាងតិច បានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់វា នឹងត្រូវមានប្រសិទ្ធភាពត្រឹមតែក្នុងរង្វង់ភាគីចុះកិច្ចសន្យា ដែលបានផ្តល់សច្ចាប័នឬការយល់ព្រមដល់ឧបសម្ព័ន្ធ ។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន ។

មាត្រា ៧.- ការកែសម្រួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវបានធ្វើការកែសម្រួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្របទៅតាមខ្លឹមសារនៃឧបសម្ព័ន្ធ ។

មាត្រា ៨.- ការដាក់លក្ខខ័ណ្ឌ

ការដាក់លក្ខខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតឡើយ ។

មាត្រា ៩.- ការព្យួរទុកនៃឧបសម្ព័ន្ធ

ភាគីចុះកិច្ចសន្យានិមួយៗអាចព្យួរទុក ជាបណ្តោះអាសន្ន នូវការអនុវត្តន៍ឧបសម្ព័ន្ធទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រសិទ្ធិភាពភ្លាមៗ នៅក្នុងករណីមានការរីករាលជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន ។ ភាគីចុះកិច្ចសន្យា នឹងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀត ភ្លាម តាមតែអាចធ្វើទៅបាន អំពីការព្យួរទុកនេះ និងការបញ្ចប់ការព្យួរទុកនេះ ឱ្យបានឆាប់បំផុត នៅពេលណាដែលសភាពការណ៍ វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ ។

មាត្រា ១០.- ទំនាក់ទំនង ជាមួយកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ឧបសម្ព័ន្ធនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនោះទេ ។ នៅក្នុងករណី ដែលវិសមិត (មិនចុះសម្រុងគ្នា) រវាងឧបសម្ព័ន្ធ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយកជាបានការ ។ នៅក្នុងករណីដែលវិសមិត(មិនចុះសម្រុងគ្នា) រវាងឧបសម្ព័ន្ធ និងឧបសម្ព័ន្ធ ឬពិធីសារផ្សេងទៀតនោះ វិសមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា នឹងកិច្ចព្រមព្រៀង ។

GMS-Annex7_kh- 01 Sep 2006 1/19/2001

មាត្រា ១១.- ទំនាក់ទំនង ជាមួយឯកសារភ្ជាប់នៅនឹងឧបសម្ព័ន្ធ

ឯកសារភ្ជាប់ ត្រូវបង្កើតជាផ្នែករួមបញ្ចូលគ្នាមួយ ជាមួយឧបសម្ព័ន្ធ និងត្រូវមានតំលៃចូលរួមស្មើៗគ្នា ។

មាត្រា ១២.- ការដោះស្រាយជំលោះ

ជំលោះរវាងភាគី០២ ឬច្រើន នៃភាគីចុះកិច្ចសន្យា នៅលើការបកស្រាយ ឬការអនុវត្តន៍ឧបសម្ព័ន្ធ ត្រូវស្រុះស្រួលគ្នាលើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចារ តាមគោលការណ៍សន្តិវិធី តាមរយៈគណៈកម្មាធិការរួម ។

មាត្រា ១៣.- ការប្រកាសបដិសេធ

នៅពេលណាដែលចូលជាធរមាន ឧបសម្ព័ន្ធមិនអាចឱ្យគេប្រកាសបដិសេធដាច់ដោយឡែក ចេញអំពីកិច្ចព្រមព្រៀងបានទេ

ឧបទានទៅនឹងឧបសម្ព័ន្ធទី ៧ :

ឧបទានទី ១ : បទបញ្ជានៅតាមផ្លូវថ្នល់

ឧបទានទី ២ : ផ្លាកសញ្ញា និងភ្លើងសញ្ញាចរាចរណ៍តាមផ្លូវថ្នល់

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដោយបានទទួលការអនុញ្ញាតពីអង្គាធរៀងៗខ្លួន បានចុះហត្ថលេខាលើឧបសម្ព័ន្ធនេះ ។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ ជា០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម ហ៊ូ ស៊ីហ៊ុី អនុរដ្ឋមន្ត្រី គមនាគមន៍

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ឯកឧត្តម សំម៉ាដ ផុលសេនា អនុរដ្ឋមន្ត្រីគមនាគមន៍ ដឹកជញ្ជូន ប៉ុស្តិ៍ និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
ឯកឧត្តម ធូរ៉ា ថេងវីន អនុរដ្ឋមន្ត្រី ដឹកជញ្ជូនផ្លូវដែក

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់
ឯកឧត្តម នីកន ចំណុង អនុរដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
ឯកឧត្តម ដាវ ឌេមិញ អនុរដ្ឋមន្ត្រីដឹកជញ្ជូន

ANNEX 7: ROAD TRAFFIC REGULATION AND SIGNAGE

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People (hereinafter referred to as "the Annex")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as "the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed on 26 November 1999 at Vientiane, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China on 3 November 2002 at Phnom Penh, and acceded to by the Union of Myanmar on 19 September 2003 at Dali City (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Articles 15 and 26 of the Agreement, calling for this Annex to provide technical details,

HAVE AGREED AS FOLLOWS:

Article 1: Road Traffic Regulation

The road traffic regulation shall be the rules of the road as prescribed in Attachment 1 to this Annex.

Article 2: Road Signs and Signals

(a) Road signs, signals, symbols, and road markings on the routes and corridors designated in Protocol 1 of the Agreement shall be as prescribed in Attachment 2 to this Annex.

(b) A transition period of four years from the date of entry into force in their territory of this Annex is allowed to the Contracting Parties to gradually replace or supplement any sign, symbol, signal, and marking on the routes and corridors designated in Protocol 1 of the Agreement, which although it has the characteristics of a sign, symbol, signal, or marking belonging to the system prescribed by Attachment 2 of this Annex is used with a different meaning from that assigned in Attachment 2.

(c) A transition period of 15 years from the date of entry into force in their territory of this Annex is allowed to the Contracting Parties to gradually replace any sign, symbol, signal, and marking on the routes and corridors designated in Protocol 1 of the Agreement, which does not conform in principle to the system prescribed by Attachment 2 of this Annex. During this period, in order to familiarize road users with the system prescribed by Attachment 2, previous signs and symbols may be retained beside those prescribed in Attachment 2.

(d) Where Attachment 2 of this Annex does not prescribe a sign, symbol, or marking to signify a certain rule or convey certain information to road users, it shall be open to the Contracting Parties to use for these purposes any sign, symbol, or marking they wish, provided that such sign, symbol, or marking is not assigned a different meaning by Attachment 2 and provided that it conforms to the system prescribed by Attachment 2.

(e) Nothing in this Annex shall be construed as requiring the Contracting Parties to adopt all types of signs and markings prescribed by Attachment 2. On the contrary, Contracting Parties shall limit the number and types of signs or markings they adopt to what is strictly necessary.

(f) The Contracting Parties undertake to prohibit on their territory to affix to or install near a sign or other traffic control device, any object, board, notice, marking or other device that makes the sign less visible and understandable or risks confusing or distracting the road user in a way prejudicial to traffic safety.

Article 3: Clarification

(a) The use of language in road markings, signs, and signals can be limited to a minimum by the use of symbols.

(b) The prescribed use of English/Latin characters and Arabic numerals by no means prohibits the parallel use of the national language.

Article 4: Amendment

Any Contracting Party may propose amendments to the Annex via the Joint Committee. Such amendments shall be subject to the unanimous consent of the Contracting Parties.

Article 5: Ratification or Acceptance

The Annex is subject to ratification or acceptance of the Governments of the Contracting Parties. The same applies to an amendment to the Annex, if any.

Article 6: Entry into Force

The Annex will enter into force on the day that at least two Contracting Parties have ratified or accepted it, and will become effective only among the Contracting Parties that have ratified or accepted it. The same applies to an amendment to the Annex, if any.

Article 7: Conforming National Law

Where necessary, the Contracting Parties undertake to conform their relevant national legislation with the contents of the Annex.

Article 8: Reservations

No reservation to the Annex shall be permitted.

Article 9: Suspension of the Annex

Each Contracting Party may temporarily suspend wholly or partly the application of the Annex with immediate effect in the case of emergencies affecting its national safety. The Contracting Party will inform the other Contracting Parties as soon as possible of such suspension, which will end as soon as the situation returns to normal.

Article 10: Relationship with the Agreement

As a measure to implement the principles laid down in the Agreement, the Annex cannot depart from or be contrary to these principles. In case of incompatibility between the Annex and the Agreement, the latter shall prevail. In case of incompatibility between the Annex and another annex or protocol, such incompatibility shall be interpreted in light of the Agreement.

Article 11: Relationship of the Attachments to the Annex

The attachments shall form an integral part of the Annex and shall be equally binding.

Article 12: Dispute Settlement

Any dispute between or among two or more Contracting Parties on the interpretation or application of the Annex shall be settled directly or by amicable negotiation in the Joint Committee.

Article 13: Denunciation

Once entered into force, the Annex cannot be denounced separately from the Agreement.

Attachments to Annex 7:

Attachment 1: Rules of the Road
Attachment 2: Roads Signs and Signals

Annex 7: Road Traffic Regulation and Signage

In witness whereof, the undersigned, being duly authorized, have signed this Annex.

Done at Phnom Penh on 30 April 2004 in six originals in the English language.

Signed:

For the Royal Government of Cambodia

....

His Excellency Tram Iv Tek
Secretary of State, Ministry of Public Works and Transport

For the Government of the People's Republic of China

....

His Excellency Hu Xijie
Vice Minister of Communications

For the Government of the Lao People's Democratic Republic

....

His Excellency Sommad Pholsena
Vice Minister of Communication, Transport, Post and Construction

For the Government of the Union of Myanmar

....

His Excellency Thura Thaung Lwin
Deputy Minister of Rail Transportation

For the Government of the Kingdom of Thailand

....

His Excellency Nikorn Chamnong
Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam

....

His Excellency Pham The Minh
Vice Minister of Transport

ឧបសម្ព័ន្ធទី ៩

លក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់បណ្ណអនុញ្ញាតដល់ប្រតិបត្តិករដឹកជញ្ជូន សំរាប់ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៏
និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

(តទៅហៅកាតថា "ឧបសម្ព័ន្ធ")

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាព មីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (តទៅហៅកាត់ថា "ភាគីចុះកិច្ចសន្យា")

ដោយយោងទៅដល់ កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាត់បូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាងហ្គូន . ដែលបានយល់ព្រមចូលដោយ ព្រះរាជាណាចក្រកម្ពុជា នៅយ៉ាងហ្គូន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០១ បានយល់ព្រមចូលដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី ហើយបានធ្វើវិសោធនកម្មនៅភ្នំពេញថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៤តទៅហៅកាត់ថា "កិច្ចព្រមព្រៀង"

ដោយយោងទៅដល់មាត្រាទី ៣(បេ)និង(អិន)នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា ។

ដោយយោងទៅដល់ មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារ និមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង ។

ដោយយោងទៅដល់ កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានិលឡា ក្នុងខែមករា ឆ្នាំ ២០០០. កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទិ១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់ បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្ហើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសារ របស់វា ក្នុងឆ្នាំ ២០០៥ និង

ដោយយោងទៅដល់ មាត្រាទី២១(អា) និង២២(អា) នៃកិច្ចព្រមព្រៀង ដែលបានស្នើឱ្យផ្តល់តាមរយៈឧបសម្ព័ន្ធនេះ នូវការរៀបចំ លំអិត ខាងបច្ចេកទេស

បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រា ១ .. សេចក្តីផ្តើម

ប្រតិបត្តិករដឹកជញ្ជូន ដែលធ្វើសកម្មភាពប្រតិបត្តិការដឹកជញ្ជូន ត្រូវបំពេញលក្ខខ័ណ្ឌទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធនេះ។

មាត្រា ២ .. មូលដ្ឋាននៃការជ្រើសរើស

ក-ប្រតិបត្តិករដឹកជញ្ជូន ត្រូវបានផ្តល់អជ្ញាប័ណ្ណដោយប្រទេសដើម ដើម្បីធ្វើសកម្មភាពប្រតិបត្តិការដឹកជញ្ជូនជាអន្តរជាតិ ដែលផ្តល់ឱ្យពួកគេទៅតាមលក្ខខ័ណ្ឌ ដែលបានកំណត់នៅមាត្រា៣.៤.៥ និង៦។

ខ- ប្រសិនបើប្រតិបត្តិករដឹកជញ្ជូន មិនមែនជារូបវ័ន្តបុគ្គល តែជានិតិបុគ្គល ឬប្រសិនបើម្ចាស់សហគ្រាសដឹកជញ្ជូនមិនបានបំពេញលក្ខខ័ណ្ឌទាំងឡាយដោយខ្លួនឯង នោះ អ្នកដែលទទួលជំនួស នូវការគ្រប់គ្រងជាប់ជាប្រចាំ និងមានប្រសិទ្ធភាព នៃសហគ្រាស ត្រូវតែបំពេញលក្ខខ័ណ្ឌទាំងឡាយ ដោយគោរពទៅតាម សមត្ថភាពជំនាញ និងដែលគួរឱ្យទុកចិត្តបាន។

គ- ប្រតិបត្តិករដឹកជញ្ជូនណាមួយដែលមិនបានបំពេញលក្ខខ័ណ្ឌជាតំរូវការទាំងនោះទេ ត្រូវបានដកហូតអជ្ញាប័ណ្ណរបស់គេ

មាត្រា ៣ .. ម្ចាស់កម្មសិទ្ធជាពលរដ្ឋ

សហគ្រាសប្រតិបត្តិការដឹកជញ្ជូន ត្រូវបំពេញទៅតាមតំរូវការដូចខាងក្រោម :

ក- សហគ្រាសប្រតិបត្តិការដឹកជញ្ជូន ត្រូវមានភាគហ៊ុនចំនួនច្រើនជាងពាក់កណ្តាល កាន់កាប់ដោយពលរដ្ឋជាតិនៃប្រទេសដើម។

ខ- សហគ្រាសដឹកជញ្ជូន ត្រូវដឹកនាំដោយ ពលរដ្ឋភាគច្រើន នៃប្រទេសដើម។

មាត្រា ៤ .. ភាពអាចជឿទុកចិត្តបាន

ប្រតិបត្តិករដឹកជញ្ជូន មិនត្រូវមាន :

ក- ទទួលទោសទ័ណ្ឌ ធ្ងន់ធ្ងរណាមួយ តាមច្បាប់ ឬក៏បទដ្ឋានគតិយុត្តិពាក់ព័ន្ធ នៃប្រទេសដើម។

ខ- ទទួលការដកហូត ចេញពីឯកទេសជំនាញ ក្នុងការអនុវត្តន៏ការងារជាអ្នកដឹកជញ្ជូនតាមផ្លូវថ្នល់ ក៏ដូចជាការ ការដាក់ទណ្ឌកម្ម ក្នុងការប្រព្រឹត្តខុស ទៅនឹងការអនុវត្តច្បាប់ ឬបទបញ្ញត្តិនៅក្នុងវិស័យដឹកជញ្ជូនផ្លូវគោក។

គ- ការប្រកាសអំពីការក្ស័យធន លើកលែងតែសិទ្ធិ សមត្ថភាពអនុវត្ត ឯកសិទ្ធិ ឬក៏ការដោះស្រាយថវិកា នៃប្រតិបត្តិករដឹកជញ្ជូន ត្រូវបានធ្វើនិតិសម្បទាឡើងវិញ ឱ្យបានសមរម្យ ស្របទៅតាមច្បាប់ ឬបទបញ្ញត្តិ នៃប្រទេសដើមរបស់ប្រតិបត្តិករដឹកជញ្ជូន។

មាត្រា ៥ .. សមត្ថភាពជំនាញ

ភាគីចុះកិច្ចសន្យា នៃប្រទេសដើមត្រូវផ្ទៀងផ្ទាត់ និងធានាសមត្ថភាពរបស់ប្រតិបត្តិករដឹកជញ្ជូន ឱ្យស្របទៅតាមគោលការណ៍ គ្រប់គ្រងសេដ្ឋកិច្ច និងការផ្គត់ផ្គង់សេវាប្រកបដោយគុណភាព ការប្រកួតប្រជែងដោយគុណភាព ការប្រកួតប្រជែងដោយតំលាភាព និងប្រតិបត្តិការដោយសុវត្ថិភាព នៃសហគ្រាសដឹកជញ្ជូន ។ សំរាប់គោលបំណងខាងលើនេះ ភាគីចុះកិច្ចសន្យាត្រូវទាមទារ ឱ្យប្រតិបត្តិករដឹកជញ្ជូន មានជំនាញប៉ិនប្រសប់នៅក្នុងវិស័យដូចខាងក្រោម :

ក- ចំណេះដឹងខាងផ្លូវច្បាប់ ដែលពាក់ព័ន្ធទៅដល់ការធ្វើជំនួញខាងដឹកជញ្ជូនតាមផ្លូវថ្នល់ (ឧ. កិច្ចសន្យា ច្បាប់សហគ្រាស ច្បាប់គណនេយ្យ ច្បាប់ពលកម្ម ច្បាប់ពន្ធអាករ ។ល។)

ខ- ការគ្រប់គ្រងប្រតិបត្តិការដឹកជញ្ជូន(ឧ.ការគណនាតំលៃ និងថ្លៃដឹកជញ្ជូន ការបង់ចំណាយ និង និតិវិធីខាងហិរញ្ញវត្ថុ បទបញ្ញត្តិនៃតំលៃ ការធានារ៉ាប់រង អង្គភាពកណ្តាលនៃការដឹកជញ្ជូន បច្ចេកទេសគ្រប់គ្រង និងការរកទីផ្សារ ។

គ- លក្ខខ័ណ្ឌ និងតំរូវការ ល្ងើការចូលទៅរកទីផ្សារប្រសិនបើមាន (ឧ. ការយល់ដឹងអំពីជំនាញឯកសារដឹកជញ្ជូន ការប្រកួតប្រជែងដោយស្មោះត្រង់បរិសុទ្ធ ការប្រយុទ្ធប្រឆាំងនឹងការបញ្ចុះថ្លៃ ឬវិច្ឆេទកម្មទីផ្សារ ។

ឃ- វិធានការបច្ចេកទេស ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការដឹកជញ្ជូន(ឧ. ទំហំ និងទំងន់នៃយានយន្ត ជំរើសយានយន្ត ការថែទាំយានយន្ត ការផ្ទុកលើកដាក់ និងផ្ទេរ យានយន្ត ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ និងទំនិញងាយខូចលួយ គោលការណ៍នៃការការពារបរិស្ថាន សំរាប់ការដឹកជញ្ជូនផ្លូវគោក ។

ង- សុវត្ថិភាពចរាចរ(ឧ. តួនាទីរបស់ផ្លូវថ្នល់ ការព្រមាន និងការសំរាលគ្រោះថ្នាក់ចរាចរ)

មាត្រា ៦ .. សមត្ថភាពផ្នែកហិរញ្ញវត្ថុ

ក- ប្រតិបត្តិករដឹកជញ្ជូន ត្រូវជាម្ចាស់កម្មសិទ្ធិលើមធ្យោបាយហិរញ្ញវត្ថុទាំងឡាយដោយមានប្រសិទ្ធភាព ដើម្បីធានានូវការប្រព្រឹត្តទៅ និងការគ្រប់គ្រងសហគ្រាសប្រតិបត្តិការដឹកជញ្ជូន ដោយសមរម្យ ។

ខ- សំរាប់គោលបំណងក្នុងការប៉ាន់ប្រមាណ សមត្ថភាពហិរញ្ញវត្ថុនៃប្រតិបត្តិករដឹកជញ្ជូន ត្រូវបំពេញនូវកត្តាដូចខាងក្រោម :

- តារាងតុល្យភាពរបស់ប្រតិបត្តិករដឹកជញ្ជូន
- ទ្រព្យសម្បត្តិ
- ឥណទានគណនីពីធនាគារ
- សមត្ថភាពទទួលបានឥណទានកំចី

- មានលិខិតធានារ៉ាប់រងពីធនាគារ
- ការធានារ៉ាប់រងលើការទទួលខុសត្រូវ ។

គ- ប្រតិបត្តិករដឹកជញ្ជូន ត្រូវមានការធានារ៉ាប់រងនៃប្រតិបត្តិករលើកិច្ចសន្យា

មាត្រា ៧.- ការធ្វើវិសោធនកម្ម

ភាគីចុះកិច្ចសន្យាណាមួយក៏ដោយ អាចស្នើធ្វើវិសោធនកម្ម លើឧបសម្ព័ន្ធ តាមរយៈគណកម្មាធិការរួម ។ ការធ្វើវិសោធនកម្មនោះ ត្រូវតែជាកម្មវត្ថុនៃការឯកភាពគ្នាជាឯកច្ឆ័ន្ទ ពីភាគីចុះកិច្ចសន្យាទាំងអស់ ។

មាត្រា ៨.- ការផ្តល់សច្ចាប័ន និងការយល់ព្រម

ឧបសម្ព័ន្ធនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រម នៃរដ្ឋាភិបាលទាំងឡាយដែលជាភាគីចុះកិច្ចសន្យា ។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន ។

មាត្រា ៩.- ការចូលជាធរមាន

ឧបសម្ព័ន្ធ នឹងត្រូវចូលជាធរមាន នៅថ្ងៃដែល ០២ភាគីចុះកិច្ចសន្យាយ៉ាងតិច បានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់វា នឹងត្រូវមានប្រសិទ្ធភាពត្រឹមតែក្នុងរង្វង់ភាគីចុះកិច្ចសន្យា ដែលបានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់ឧបសម្ព័ន្ធ ។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន ។

មាត្រា ១០.- ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវធានាធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្របទៅតាមខ្លឹមសារនៃឧបសម្ព័ន្ធ ។

មាត្រា ១១.- ការដាក់លក្ខខ័ណ្ឌ

ការដាក់លក្ខខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតិឡើយ ។

មាត្រា ១២.- ការព្យួរទុកនៃឧបសម្ព័ន្ធ

ភាគីចុះកិច្ចសន្យានិមួយៗអាចព្យួរទុក ជាបណ្តោះអាសន្ន នូវការអនុវត្តន៍ឧបសម្ព័ន្ធទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រសិទ្ធិភាពភ្លាមៗ នៅក្នុងករណីមានការរីករាលដាលអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន ។ ភាគីចុះកិច្ចសន្យា នឹងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀត ភ្លាម តាមតែអាចធ្វើទៅបាន អំពីការព្យួរទុកនេះ និងការបញ្ចប់ការព្យួរទុកនេះ ឱ្យបានឆាប់បំផុត នៅពេលណា ដែលសភាពការណ៍ វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ ។

មាត្រា ១៣.- ទំនាក់ទំនង ជាមួយកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ឧបសម្ព័ន្ធនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនោះ ។ នៅក្នុងករណី ដែលវិសមិត (មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយកជាបានការ ។ នៅក្នុងករណីដែល វិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងឧបសម្ព័ន្ធ ឬពិធីសារផ្សេងទៀតនោះ វិសមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា នឹងកិច្ចព្រមព្រៀង ។

មាត្រា ១៤.. ការដោះស្រាយជំលោះ

ជំលោះរវាងភាគី០២ ឬច្រើន នៃភាគីចុះកិច្ចសន្យា នៅលើការបកស្រាយ ឬការអនុវត្តន៍ឧបសម្ព័ន្ធ ត្រូវស្រុះស្រួលគ្នា លើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចារតាមគោលការណ៍សន្តិវិធី តាមរយៈគណៈកម្មាធិការរួម ។

មាត្រា ១៥.. ការប្រកាសបដិសេធ

នៅពេលណាដែលចូលជាធរមាន ឧបសម្ព័ន្ធមិនអាចឱ្យគេប្រកាសបដិសេធដាច់ដោយឡែក ចេញអំពីកិច្ចព្រមព្រៀងបានទេ ។

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលការអនុញ្ញាតពីរដ្ឋាធរៀងៗខ្លួន បានចុះហត្ថលេខាលើឧបសម្ព័ន្ធនេះ ។

ធ្វើនៅ វៀងច័ន្ទ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ ជា០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តម **ឃី តាំងលីម** ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីទទួលបន្ទុកសហប្រតិបត្តិការមហាអនុតំបន់មេគង្គ

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម **លាវ ស៊ាវយន់** អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ឯកឧត្តម **សំម៉ាដ ផុលសេនា** អនុរដ្ឋមន្ត្រីគមនាគមន៍ ដឹកជញ្ជូន ប្រៃសណីយ៍ និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
ឯកឧត្តម **ស៊ូ ថា** រដ្ឋមន្ត្រីអភិវឌ្ឍផែនការ និងសេដ្ឋកិច្ចជាតិ

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍
ឯកឧត្តម **នីភន ចំណុង** អនុរដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
ឯកឧត្តម **ចាន់ ហ្សឺនខៀន** អនុរដ្ឋមន្ត្រី ផែនការ និងវិនិយោគ

ANNEX 9: CRITERIA FOR LICENSING OF TRANSPORT OPERATORS FOR CROSS-BORDER TRANSPORT OPERATIONS

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for Facilitation of Cross-Border Transport of Goods and People (hereinafter referred to as "the Annex")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as "the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed at Vientiane on 26 November 1999, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China at Phnom Penh on 3 November 2002, and acceded to by the Union of Myanmar at Dali City on 19 September 2003, and amended at Phnom Penh on 30 April 2004 (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Articles 21(a) and 22(a) of the Agreement, calling for this Annex to provide technical details,

HAVE AGREED AS FOLLOWS:

Annex 9: Criteria for Licensing of Transport Operators for Cross-Border Transport Operations

Article 1: Introduction

Transport Operators who perform international transport operations shall fulfill all conditions laid down in this Annex.

Article 2: Basic Eligibility

(a) Transport Operators shall be licensed by their Home Country to perform international transport operations provided they meet the minimum conditions set out in Articles 3, 4, 5, and 6 of this Annex.

(b) If the Transport Operator is not a physical but a legal person or if the owner of the transport enterprise does not fulfill the conditions himself/herself, the person who is in charge of the permanent and effective management of the enterprise must fulfill the conditions with respect to reliability and professional competence.

(c) A Transport Operator that no longer meets the requirements shall be divested of his/her license.

Article 3: Substantial Ownership by National Citizens

The transport operation enterprise shall comply with the following requirements:

(a) More than half of the transport operation enterprise's capital must be owned by national citizens of the Home Country.

(b) The enterprise must also be directed by a majority of national citizens of the Home Country

Article 4: Reliability

The Transport Operator must not have been:

(a) convicted for serious breaches of relevant laws or regulations of the Home Country; or

(b) divested from the capacity to exercise the profession of road carrier as a sanction for breach of applicable laws or regulations in the field of road carriage; or

(c) declared bankrupt unless the rights, competency, privileges, or financial solvency of the Transport Operator have been restored or rehabilitated, as appropriate, according to the laws or regulations of the Home Country of the Transport Operator.

Article 5: Professional Competence

The Home Country Contracting Party shall verify and make sure of the Transport Operator's ability for sound economic management, supply of quality service, fair competition, and safe operation of the transport enterprise. For that purpose the Contracting Party shall require the Transport Operator to be proficient in the following fields:

t + S.P. a.d.

Annex 9: Criteria for Licensing of Transport Operators for Cross-Border Transport Operations

Article 1: Introduction

Transport Operators who perform international transport operations shall fulfill all conditions laid down in this Annex.

Article 2: Basic Eligibility

(a) Transport Operators shall be licensed by their Home Country to perform international transport operations provided they meet the minimum conditions set out in Articles 3, 4, 5, and 6 of this Annex.

(b) If the Transport Operator is not a physical but a legal person or if the owner of the transport enterprise does not fulfill the conditions himself/herself, the person who is in charge of the permanent and effective management of the enterprise must fulfill the conditions with respect to reliability and professional competence.

(c) A Transport Operator that no longer meets the requirements shall be divested of his/her license.

Article 3: Substantial Ownership by National Citizens

The transport operation enterprise shall comply with the following requirements:

(a) More than half of the transport operation enterprise's capital must be owned by national citizens of the Home Country.

(b) The enterprise must also be directed by a majority of national citizens of the Home Country.

Article 4: Reliability

The Transport Operator must not have been:

(a) convicted for serious breaches of relevant laws or regulations of the Home Country; or

(b) divested from the capacity to exercise the profession of road carrier as a sanction for breach of applicable laws or regulations in the field of road carriage; or

(c) declared bankrupt unless the rights, competency, privileges, or financial solvency of the Transport Operator have been restored or rehabilitated, as appropriate, according to the laws or regulations of the Home Country of the Transport Operator.

Article 5: Professional Competence

The Home Country Contracting Party shall verify and make sure of the Transport Operator's ability for sound economic management, supply of quality service, fair competition, and safe operation of the transport enterprise. For that purpose the Contracting Party shall require the Transport Operator to be proficient in the following fields:

t. + s.l.   a. d.

(a) legal matters relevant to the road transport business (e.g., contracts, carrier liability, company law, accounting law, labor law, tax law);

(b) transport operation management (e.g., cost and price calculation, payment and financing methods, price regulation, insurance, transport intermediaries, management techniques, marketing);

(c) conditions and requirements on access to the market, if any (e.g., access to the profession, transport documents, fair competition/anti-dumping);

(d) technical matters relating to transport operations (e.g., sizes and weights of vehicles, choice of vehicle, maintenance of the vehicle, loading and unloading of the vehicle, carriage of dangerous and perishable goods, principles of environmental protection in road traffic); and

(e) road safety (e.g., rules of the road, traffic accident prevention and mitigation).

Article 6: Financial Solvency

(a) The Transport Operator shall own sufficient financial means to guarantee the proper functioning and management of the transport operation enterprise.

(b) For the purpose of assessing the Transport Operator's solvency, the following elements may be taken into account: the Transport Operator's balance sheet, assets, bank account credit, capacity to obtain loans, bank guarantees obtained, and liability insurance cover.

(c) The Transport Operator must carry insurance covering the Operator's contractual liability.

Article 7: Amendment

Any Contracting Party may propose amendments to the Annex via the Joint Committee. Such amendments shall be subject to the unanimous consent of the Contracting Parties.

Article 8: Ratification or Acceptance

For the Royal Government of Cambodia

....
His Excellency Tram Iv Tek
Secretary of State, Ministry of Public Works and Transport

For the Government of the People's Republic of China

....
His Excellency Hu Xijie
Vice Minister of Communications

For the Government of the Lao People's Democratic Republic

....
His Excellency Sommad Pholsena
Vice Minister of Communication, Transport, Post and Construction

For the Government of the Union of Myanmar

....
His Excellency Thura Thaung Lwin
Deputy Minister of Rail Transportation

For the Government of the Kingdom of Thailand

....
His Excellency Nikorn Chamnong
Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam

....
His Excellency Pham The Minh
Vice Minister of Transport

ANNEX 11: ROAD AND BRIDGE DESIGN AND CONSTRUCTION STANDARDS AND SPECIFICATIONS

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People (hereinafter referred to as "the Annex")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as "the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed on 26 November 1999 at Vientiane, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China on 3 November 2002 at Phnom Penh, and acceded to by the Union of Myanmar on 19 September 2003 at Dali City (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Article 25 of the Agreement, calling for this Annex to provide technical details,

GMS-Annex13a_kh-01 Sep 2006 1/19/2001

ឧបសម្ព័ន្ធ ១៣អា

របបគ្រប់គ្រងការទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុភាព

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

(តទៅហៅកាត់ថា " ឧបសម្ព័ន្ធ ")

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (តទៅហៅកាត់ថា " ភាគីចុះកិច្ចសន្យា ")

ដោយយោងទៅលើ កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាតំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាំងហ្គូន ; ដែលបានយល់ព្រមចូល ដោយព្រះរាជាណាចក្រកម្ពុជា នៅយ៉ាំងហ្គូន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ បានយល់ព្រមចូល ដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី តទៅហៅកាត់ថា " កិច្ចព្រមព្រៀង "

ដោយយោងទៅលើមាត្រាទី ៣(បេ)និង(អិន)នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា

ដោយយោងទៅលើ មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង

ដោយយោងទៅលើ កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានិលឡា ក្នុងខែមករា ឆ្នាំ ២០០០. កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទី១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់ បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្ហើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសាររបស់វា ក្នុងឆ្នាំ ២០០៥ និង

ដោយយោងទៅលើ មាត្រា៣៤(អា) នៃកិច្ចព្រមព្រៀង ដែលបានស្នើឱ្យផ្តល់តាមរយៈឧបសម្ព័ន្ធនេះ នូវការរៀបចំលំអិតខាងបច្ចេកទេស

បានព្រមព្រៀងគ្នាដូចខាងក្រោម :

GMS-Annex13a_kh-01 Sep 2006 1/19/2001

មាត្រា ១.- របបគ្រប់គ្រងការទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុរូបភាព

របបគ្រប់គ្រងការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនពហុរូបភាព ត្រូវបានគេបកស្រាយ នៅក្នុងឯកសារភ្ជាប់នៃឧបសម្ព័ន្ធ នេះ "**របបទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុរូបភាព**" ។

មាត្រា ២.- ការធ្វើវិសោធនកម្ម

ភាគីនៃកិច្ចសន្យាអាចស្នើសុំការធ្វើវិសោធនកម្មទៅលើពិធីសារនេះ តាមរយៈគណៈកម្មាធិការរួម ។ ការធ្វើវិសោធនកម្មបែបនេះនឹងត្រូវជាកម្មវត្ថុនៃការយល់ព្រមជាឯកឆន្ទ័នៃភាគីនៃកិច្ចសន្យាទាំងអស់ ។

មាត្រា ៣.- ការផ្តល់សច្ចាប័ន ឬការយល់ព្រមទទួលយក

ពិធីសារនេះ គឺជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រមទទួលយករបស់រដ្ឋាភិបាលនៃភាគីកិច្ចសន្យា ។ ការអនុវត្តន៍ដូចៗគ្នានេះ ត្រូវបានគេអនុវត្តចំពោះការធ្វើវិសោធនកម្មទៅលើពិធីសារ ប្រសិនបើមាន ។

មាត្រា ៤.- ការចូលជាធរមាន

ពិធីសារនឹងចូលជាធរមាននៅថ្ងៃដែលមានភាគីនៃកិច្ចសន្យាចំនួនពីរយ៉ាងតិច បានផ្តល់សច្ចាប័នឬការយល់ព្រមទទួលយក ហើយនិងត្រូវមានប្រសិទ្ធិភាពនៅត្រឹមតែក្នុងចំណោមភាគីនៃកិច្ចសន្យាដែលបានផ្តល់សច្ចាប័នឬការយល់ព្រមទទួលយក ពិធីសារនេះប៉ុណ្ណោះ ។ ការអនុវត្តដូចៗគ្នា ត្រូវបានគេអនុវត្តចំពោះការធ្វើវិសោធនកម្មទៅលើពិធីសារ ប្រសិនបើមាន ។

មាត្រា ៥. ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវបានធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្របទៅតាមខ្លឹមសារនៃពិធីសារ ។

មាត្រា ៦.- ការដាក់លក្ខខ័ណ្ឌ

ការដាក់លក្ខខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតិឡើយ ។

មាត្រា ៧.- ការព្យួរទុកនូវពិធីសារ

ភាគីចុះកិច្ចសន្យានិមួយៗអាចព្យួរទុក ជាបណ្តោះអាសន្ន នូវការអនុវត្តន៍ពិធីសារទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រសិទ្ធិភាពភ្លាមៗ នៅក្នុងករណីមានការវិវត្តជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន។ ភាគីចុះកិច្ចសន្យា ត្រូវជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀតភ្លាមៗតាមតែអាចធ្វើទៅបាន អំពីការព្យួរទុក និងការបញ្ចប់ការព្យួរទុកនេះឱ្យបានឆាប់បំផុត នៅពេលណាដែលសភាពការណ៍វិលត្រឡប់ ទៅរកស្ថានភាពជាធម្មតាឡើងវិញ។

មាត្រា ៨.- សម្ព័ន្ធភាពជាមួយនឹងកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ពិធីសារនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនេះបានទេ។ នៅក្នុងករណីដែលវិសមិត (មិនចុះសំរុងគ្នា) រវាងពិធីសារ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយកជាបានការ។ នៅក្នុងករណីដែលវិសមិត(មិនចុះសំរុងគ្នា)រវាងពិធីសារ និងឧបសម្ព័ន្ធ ឬពិធីសារផ្សេងទៀតនោះ វិសមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា នឹងកិច្ចព្រមព្រៀង។

មាត្រា ៩.- ការដោះស្រាយជំលោះ

ជំលោះណាមួយរវាងឬក្នុងភាគី០២ ឬច្រើននៃភាគីចុះកិច្ចសន្យា ទៅលើការបកស្រាយ ឬការអនុវត្តន៍ពិធីសារ ត្រូវស្រុះស្រួលគ្នា លើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចាតាមគោលការណ៍សន្តិវិធីតាមរយៈគណៈកម្មាធិការរួម។

GMS-Annex13a_kh-01 Sep 2006 1/19/2001

មាត្រា ១០.. ការប្រកាសបដិសេធ

នៅពេលចូលជាធរមាន ពិធីសារមិនអាចត្រូវបានគេប្រកាសបដិសេធ ដាច់ដោយឡែកចេញពីកិច្ចព្រមព្រៀងបានទេ ។

កសារយោងនៃឧបសម្ព័ន្ធទី១៣ៈ របបគ្រប់គ្រង់ទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុភាព

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដោយមានការផ្តល់សិទ្ធិប្រទានយ៉ាងពេញលេញពីអង្គាធរៀង១ខ្លួន បានចុះហត្ថលេខាលើពិធីសារនេះ ។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ ជា០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម ហ៊ូ ស៊ីហ្ស៊ី អនុរដ្ឋមន្ត្រី គមនាគមន៍

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ឯកឧត្តម សំម៉ាដ ផុលសេនា អនុរដ្ឋមន្ត្រីគមនាគមន៍ ដឹកជញ្ជូន ប៉ុស្តិ៍ និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
ឯកឧត្តម ធូរ៉ា ថេងវីន អនុរដ្ឋមន្ត្រី ដឹកជញ្ជូនផ្លូវដែក

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់
ឯកឧត្តម នីភន ចំណុង អនុរដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
ឯកឧត្តម ផាំ ថេមិញ អនុរដ្ឋមន្ត្រីដឹកជញ្ជូន

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

ឯកសារភ្ជាប់ : នីតិវិធីនៃការទទួលខុសត្រូវការដឹកជញ្ជូនពហុរូបភាព

ជំពូកទី ១

និយមន័យ

មាត្រា ១

សំរាប់គោលបំណងនៃឯកសារភ្ជាប់នេះ :

" អ្នកដឹកជញ្ជូន " មានន័យថា បុគ្គលដែលអនុវត្ត ឬទទួលរ៉ាប់រងក្នុងការអនុវត្តន៍ការដឹកជញ្ជូន ឬ ក៏ផ្នែកណាមួយនៃការដឹកជញ្ជូននោះ ទោះជាបុគ្គលនោះគឺជា (ដូចគ្នាសុទ្ធសាធទៅនឹង) ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពឬក៏មិនមែនក៏ដោយ ។

" អង្គភាពជាតិមានសមត្ថកិច្ច " មានន័យថាមន្ត្រី ឬអង្គភាពដែលជ្រើសរើសដោយប្រទេសសមាជិកនិមួយៗ ។

" អ្នកទទួលទំនិញ " មានន័យថាបុគ្គលដែលមានសិទ្ធិទទួលទំនិញពីប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ។

" អ្នកផ្តល់ទំនិញ " មានន័យថា ជាបុគ្គលដែលបានសំរេចចិត្តចុះហត្ថលេខាលើកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពជាមួយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ។

" អ្នកប្រគល់ " ការប្រគល់ " ឬ បែងចែក មានន័យថា :

ក- ការប្រគល់ទំនិញទាំងឡាយទៅអោយអ្នកទទួលទំនិញ ឬ

ខ- ការផ្ទេរដាក់ទំនិញអោយនៅចំកន្លែងទៅតាមបំណងប្រាថ្នារបស់អ្នកទទួលទំនិញ ដោយអនុលោមទៅតាមកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព ឬ ទៅតាមច្បាប់ ឬ ទម្លាប់ប្រើប្រាស់ការធ្វើពាណិជ្ជកម្មជាពិសេសដោយឡែកដែលអាចអនុវត្តបាននៅទីកន្លែងប្រគល់ទំនិញ ។ ឬ

គ- ការប្រគល់ទំនិញទៅអោយអាជ្ញាធរណាមួយ ឬភាគីទី ៣ ណាមួយផ្សេងទៀតជាបុគ្គលកំណត់ ដែលទំនិញត្រូវបានគេប្រគល់ទៅអោយ ដោយអនុលោមទៅតាមច្បាប់ ឬ បទប្បញ្ញត្តិនានាដែលអាចអនុវត្តបាននៅកន្លែងប្រគល់នោះ ។

" ទំនិញ " មានន័យថា ជាទ្រព្យសម្បត្តិណាមួយ ក៏ដូចជាកុងតែន័រ ប៉ាលែត (ទំនិញជាប៉ាលែត) ឬ ផ្លាតហ្វម ឬ វត្ថុដឹកជញ្ជូនទាំងឡាយប្រហាក់ប្រហែល ឬ ការវេចខ្ចប់កញ្ចប់ទាំងឡាយ ដែលមិនមែនផ្តល់ដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពដោយមិនគិតថាមធ្យោបាយ ឬទ្រព្យសម្បត្តិទាំងនេះត្រូវបានគេដឹកជញ្ជូន ឬ ដាក់ទំនិញដឹកជញ្ជូនពីលើ ឬ ពីក្រោមវាយ៉ាងណានោះទេ ។

" ជាលាយល័ក្ខអក្សរ " រាប់បញ្ចូលទាំងទូរលេខ ទូរសារ ទូរពុម្ព ឬ មធ្យោបាយទាំងឡាយផ្សេងទៀត ដែលបោះពុម្ព ថត ឬ កត់បញ្ចូល ឬ គ្រាប់ឡើងវិញ ឬបញ្ជូនសារដោយឧបករណ៍ ឬបរិធានមេកានិច ឬអេឡិកត្រូនិក ឬ ដោយឧបករណ៍ ឬបរិធានទាំងឡាយផ្សេងទៀតបង្កើតឡើងសំរាប់បំរើគោលដៅ ដូចខាងលើនេះ ។

"ដឹកជញ្ជូនពហុរូបភាពអន្តរជាតិ " មានន័យថាការដឹកនាំទំនិញ ដោយមធ្យោបាយដឹកជញ្ជូនយ៉ាងតិច ពីរបែបខុសគ្នាលើមូលដ្ឋានកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពមួយ ពីកន្លែងមួយរបស់ប្រទេសមួយ ដែលនៅទីនោះទំនិញត្រូវបានប្រគល់ទៅអោយ ឬ ទទួលយកដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពទៅកាន់កន្លែងមួយទៀត ដែលបានកំណត់សំរាប់ប្រគល់បែងចែកទំនិញដែលស្ថិតនៅក្នុងប្រទេសដទៃមួយផ្សេងទៀត ។

ប្រតិបត្តិការទាំងឡាយក្នុងការលើកដាក់ទំនិញ និងការបែងចែកទំនិញដែលបានធ្វើឡើងក្រៅពីសកម្មភាពនៃកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពមួយដូចដែលបានកំណត់ក្នុងកិច្ចសន្យាខាងលើ និងមិនត្រូវចាត់ទុកថាជាការដឹកជញ្ជូនពហុរូបភាពអន្តរជាតិទេ ។

" ច្បាប់ចាំបាច់ " មានន័យថា ច្បាប់ ឬ អនុសញ្ញាអន្តរជាតិណាក៏ដោយ ដែលបង្កើតជាផ្នែក នៃច្បាប់របស់ជាតិពាក់ព័ន្ធដល់ការដឹកជញ្ជូនទំនិញ ដែលមាត្រាទាំងឡាយបទប្បញ្ញត្តិនៃច្បាប់ទាំងនេះមិនអាច ផ្តាច់ចេញដោយសារបដិញ្ញត្តិនៃកិច្ចសន្យា (ការចែងក្នុងកិច្ចសន្យា) ដែលបណ្តាលអោយខូចខាតប្រយោជន៍ដល់អ្នកដឹកជញ្ជូន ឬ អ្នកផ្ញើទំនិញទេ ។

" ប្រទេសសមាជិក " មានន័យថា ជាប្រទេសមួយនៃបណ្តាប្រទេសអាស៊ាន ។

" កិច្ចសន្យាដឹកជញ្ជូនពហុរូបភាព " មានន័យថា ជាកិច្ចសន្យាមួយដែលតាមរយៈនេះ ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពមួយទទួលរ៉ាប់រងទៅនឹងការទូទាត់សោហ៊ុយដឹកជញ្ជូនទំនិញ ដើម្បីអនុវត្ត ឬ ទទួលអនុវត្តនូវសកម្មភាពនៃការដឹកជញ្ជូនពហុរូបភាពជាអន្តរជាតិ ។

" ឯកសារដឹកជញ្ជូនពហុរូបភាព " មានន័យថា ឯកសារមួយដែលជាភ័ស្តុតាងបញ្ជាក់ពីកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពមួយដែលទទួលផ្ទុកនូវទំនិញដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព និងការទទួលរ៉ាប់រងដោយបុគ្គលនោះក្នុងការប្រគល់ទំនិញដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ។

" ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព " មានន័យថា បុគ្គលណាក៏ដោយក្នុងនាមខ្លួនផ្ទាល់ ឬតាមរយៈបុគ្គលដ៏ទៃផ្សេងទៀតដែលធ្វើសកម្មភាពក្នុងនាមរបស់បុគ្គលនោះ សំរេចចិត្តចុះកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពមួយ និងអ្នកដែលធ្វើសកម្មភាពជាសំខាន់នាំមុខគេ (Principle) ដែលពុំមែនជាភ្នាក់ងារណាមួយ នៃ ឬ ក្នុងនាមនៃអ្នកបញ្ជូនទំនិញ ឬ នៃអ្នកដឹកជញ្ជូនទាំងឡាយដែលចូលរួមក្នុងប្រតិបត្តិការដឹកជញ្ជូនពហុរូបភាព និងជាអ្នកដែលសន្មត់ថាជាអ្នកទទួលខុសត្រូវលើសកម្មភាពអនុវត្តនៃកិច្ចសន្យា ។

" វិញ្ញាបនប័ត្រចុះបញ្ជីការ " មានន័យថា ឯកសារចេញដោយមន្ត្រី/អង្គភាពជាតិមានសមត្ថកិច្ចដែលបញ្ជាក់ថាប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពត្រូវបានសំរេចបញ្ចូលក្នុងបញ្ជី នៃអ្នកប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពទាំងឡាយ និងកំពុងត្រូវបានអនុញ្ញាតអោយធ្វើសកម្មភាពដូចខាងលើនេះ ។

" សិទ្ធិដកប្រាក់ពិសេស (SDR) " មានន័យថា ឯកតាគណនី ដូចបានកំណត់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។

" ទទួលផ្ទុកទំនិញ ឬទទួលទំនិញអោយនៅក្រោមការទទួលខុសត្រូវរបស់នណាម្នាក់ ឬការទទួលបន្ទុក " មានន័យថា ទំនិញត្រូវបានប្រគល់ទៅអោយ និងយល់ព្រមដឹកជញ្ជូនដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ។

ជំពូកទី ២
ទំហំនៃការអនុវត្តន៏
មាត្រា ២

ឯកសារភ្ជាប់នេះនឹងអនុវត្តនៅលើ :

ក- រាល់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពទាំងអស់ ដែលនៅក្រោមការចុះបញ្ជីការរបស់អង្គភាពជាតិមានសមត្ថកិច្ចនិមួយៗ និង

ខ- រាល់កិច្ចសន្យាដឹកជញ្ជូនពហុរូបភាពទាំងអស់ សំរាប់បំរើគោលបំណងក្នុងការរៀបចំបណ្តឹងស៊ីវិលប្រសិនបើ :

(១) ទីកន្លែងសំរាប់ទទួលផ្ទុកទំនិញ ដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ដូចមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពស្ថិតនៅក្នុងប្រទេសសមាជិកណាមួយ ឬ

(២) - ទីកន្លែងប្រគល់ទំនិញដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ដូចមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព គឺស្ថិតនៅក្នុងប្រទេសជាសមាជិកមួយ ។

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

មាត្រា ៣

ទោះជាពេលណាក៏ដោយ នៅក្នុងកិច្ចព្រមព្រៀងនេះ និងនៅក្នុងប្បញ្ញត្តិដែលបានអនុម័តសំរាប់គោលបំណង នៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះ វាក្យខ័ណ្ឌណាមួយក្នុងចំណោមវាក្យខ័ណ្ឌដូចខាងក្រោម គឺត្រូវបានប្រើសំរាប់អនុវត្តកិច្ចព្រមពៀងនេះ " ដឹកជញ្ជូនពហុរូបភាព " "ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព " "កិច្ចសន្យាដឹកជញ្ជូនពហុរូបភាព " ឬ " ឯកសារដឹកជញ្ជូនពហុរូបភាព " ត្រូវបានគេទទួលស្គាល់ជាធម្មតាដូចគ្នានឹងពាក្យថា " អន្តរជាតិ " ដែរ ។

ជំពូកទី ៣

ឯកសារដឹកជញ្ជូនពហុរូបភាព

មាត្រា ៤

១- នៅពេលទំនិញត្រូវទទួលផ្ទុកដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ប្រតិបត្តិករនោះត្រូវមានឯកសារដឹកជញ្ជូនពហុរូបភាពមួយ ដែលមានទំរង់អាចចរចាបាន ឬ ពុំអាចចរចាបានទៅតាមការជ្រើសរើសរបស់ម្ចាស់ទំនិញ ។

២- ឯកសារដឹកជញ្ជូនពហុរូបភាពនឹងត្រូវចុះហត្ថលេខាដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ឬ ដោយបុគ្គលដែលបានទទួលសិទ្ធិអំណាចពីប្រតិបត្តិករនោះ ។

៣- ហត្ថលេខានៅលើឯកសារដឹកជញ្ជូនពហុរូបភាព អាចជាហត្ថលេខាដោយដៃ បោះពុម្ពក្នុងទូរពុម្ព ចោះប្រហោង បោះត្រា ជាសញ្ញា ឬជាមធ្យោបាយមេកានិក ឬអេឡិចត្រូនិកផ្សេងទៀត ប្រសិនបើមិនជំទាស់ទៅនឹងច្បាប់នៃប្រទេសប្រទេស ដែលនៅទីនោះឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានគេចេញអោយ ។

មាត្រា ៥

១- ឯកសារដឹកជញ្ជូនពហុរូបភាពនឹងត្រូវមានចំណុចពិសេសដូចតទៅ :

ក- ប្រភេទជាធម្មតាទូទៅនៃទំនិញ និមិត្តសញ្ញាចាំបាច់សំរាប់សំគាល់ទំនិញ និងការបញ្ជាក់ជាក់លាក់ដូចជាលក្ខណៈងាយខូច ឬលក្ខណៈគ្រោះថ្នាក់នៃទំនិញ ប្រសិនបើជាអាចអនុវត្តបាន បរិមាណកញ្ចប់ ឬ បំណែកទំងន់ទាំងសបក នៃទំនិញ ឬ បរិមាណរបស់ទំនិញដែលមានការបញ្ជាក់ផ្សេងពីនេះ និងរាល់ចំណុចពិសេសតាមការផ្តល់ពីអ្នកបញ្ជូនទំនិញ

ខ- ទិដ្ឋភាពខាងក្រៅនៃទំនិញ

គ- ឈ្មោះ និងទីកន្លែងធ្វើការសំខាន់ៗរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព

ឃ- ឈ្មោះនៃអ្នកផ្តល់ទំនិញ

ង- អ្នកទទួលទំនិញ ប្រសិនបើបានកំណត់ឈ្មោះដោយអ្នកផ្តល់ទំនិញ

ច- ទីកន្លែង និង កាលបរិច្ឆេទនៃការទទួលផ្ទុកទំនិញដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព

ឆ- ទីកន្លែងប្រគល់ទំនិញ

ជ- កាលបរិច្ឆេទ ឬរយៈពេលប្រគល់ទំនិញនៅទីកន្លែងប្រគល់ទំនិញ ប្រសិនបើបានព្រមព្រៀងគ្នាជាក់លាក់រវាងគូរភាគី

ឈ- បញ្ជាក់ថា តើឯកសារដឹកជញ្ជូនពហុរូបភាពអាចចរចាបាន ឬ មិនអាចចរចាបាន

ញ- ទីកន្លែង និង កាលបរិច្ឆេទការចេញឯកសារដឹកជញ្ជូនពហុរូបភាព

ដ- ហត្ថលេខានៃប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ឬបុគ្គលដែលទទួលអំណាចពីប្រតិបត្តិករនោះ

ឋ- បរិមាណទំនិញសំរាប់បែបដឹកជញ្ជូននិមួយៗ ប្រសិនបើឯកភាពគ្នាជាក់លាក់រវាងគូរភាគី ឬបរិមាណទំនិញរាប់បញ្ចូលទាំងរូបិយវត្ថុរបស់ខ្លួនក្នុងករឹតអាចទូទាត់បានដោយអ្នកទទួលទំនិញ ឬ គំរុយ (ឬ សុចនាករ) ផ្សេងទៀតដែលសោហ៊ុយដឹកជញ្ជូនអាចទូទាត់បានដោយអ្នកទទួលទំនិញ

ឌ- ផ្លូវដែលត្រូវប្រកាន់យកបែបនៃការដឹកជញ្ជូន និងទីកន្លែងផ្ទេរទំនិញ ប្រសិនបើអាចដឹងបាននៅពេលដែលឯកសារដឹកជញ្ជូនពហុរូបភាព ត្រូវបានគេចេញអោយ

ឍ- ចំណុចពិសេសផ្សេងទៀតណាមួយ ដែលបណ្តាភាគីអាចព្រមព្រៀងដាក់បញ្ចូលទៅក្នុងឯកសារពហុដឹកជញ្ជូន ប្រសិនបើមិនប្រឆាំងជាមួយនឹងច្បាប់នៃប្រទេសដែលឯកសារត្រូវបានគេចេញអោយ ។

២- អវត្តមានចេញពីឯកសារដឹកជញ្ជូនពហុរូបភាពនូវចំណុចមួយ ឬ ចំណុចច្រើននៅក្នុងចំណោមចំណុចពិសេសនានា យោងតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ នឹងមិនប៉ះពាល់ដល់លក្ខណៈស្របច្បាប់ នៃឯកសារដែលជាឯកសារដឹកជញ្ជូនពហុរូបភាព ។

មាត្រា ៦

១- ឯកសារដឹកជញ្ជូនពហុរូបភាព នឹងត្រូវចាត់ទុកជាភស្តុតាង ***តំបូងបំផុត*** ក្នុងការទទួលផ្ទុកទំនិញធ្វើឡើងដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព នូវទំនិញទាំងឡាយដែលបានរៀបរាប់ក្នុងឯកសារនោះ លើកលែងតែគំរុយផ្ទុយពីនេះដូចជា "ទំងន់សរុបទំងន់បន្ទុក និងចំនួននៃបន្ទុក" "Shipper's weight, load and count" "សំបកកញ្ចប់កុងតែន័រសំរាប់ផ្ទុក" "Shipper- Packet container" ឬ សេចក្តីបញ្ជាក់ប្រហាក់ប្រហែលដែលគេរៀបចំឡើង ដើម្បីដាក់ចូលទៅក្នុងអត្ថបទបោះពុម្ព ឬ ប្រថាប់នៅលើឯកសារនោះ ។

២- ភស្តុតាងដែលផ្ទុយពីនេះ មិនអាចទទួលយកបានឡើយ កាលណាឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្ទេរ ឬ ក៏សារប្តូរទិន្នន័យអេឡិចត្រូនិក មានតំលៃដូចគ្នាត្រូវបានបញ្ជូន និងបានទទួលដោយអ្នកទទួលទំនិញ ដែលជាអ្នកទទួលទំនិញដោយក្តីស្មោះត្រង់ បានពឹងផ្អែក និងចាត់ចែងសកម្មភាពជាបន្តបន្ទាប់ទៀត ។

ជំពូកទី ៤
ការទទួលខុសត្រូវរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព

មាត្រា ៧

ការទទួលខុសត្រូវរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ចំពោះទំនិញក្រោមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ មានរយៈពេលចាប់ពីថ្ងៃប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពបានទទួលយកទំនិញអោយមកស្ថិតនៅក្នុងបន្ទុករបស់ខ្លួន រហូតដល់ពេលប្រគល់ទំនិញទាំងនោះ ។

មាត្រា ៨

ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ត្រូវទទួលខុសត្រូវចំពោះសកម្មភាព និងការខ្វះខាតនៃអ្នកបំរើសេវា ឬ ភ្នាក់ងាររបស់គេ នៅពេលណាអ្នកបំរើសេវា ឬ ភ្នាក់ងារទាំងនោះធ្វើសកម្មភាពក្នុងក្របខ័ណ្ឌនៃកិច្ចការរបស់គេ ឬ នៃបុគ្គលផ្សេងណាមួយទៀត ដែលជាអ្នកធ្វើសេវានេះ ហើយដែលគាត់ប្រើដើម្បីសកម្មភាព នៃកិច្ចសន្យានេះ ប្រសិនបើសកម្មភាព និងការខ្វះខាតទាំងនេះគឺជាសកម្មភាពរបស់គាត់ ។

មាត្រា ៩

ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ត្រូវទទួលរ៉ាប់រងអនុវត្ត ឬ ប្រគល់ការអនុវត្តន៍រាល់សកម្មភាពចាំបាច់ ដើម្បីធានានូវការប្រគល់ទំនិញ :

ក- នៅពេលណាដែលឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្តល់ក្នុងទំរង់អាចចរចាបាន ទៅអោយ "អ្នកកាន់" ដែលបុគ្គលមានកាន់ឯកសារដើម ១ ច្បាប់ ឬ

ខ- នៅពេលណាឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្តល់ក្នុងទំរង់អាចចរចាបាន "តាមការបញ្ជា" ទៅអោយបុគ្គលដែលមានឯកសារដើមមួយច្បាប់ ដោយមានចំណារឯកភាពត្រឹមត្រូវតាមច្បាប់ ឬ

គ- នៅពេលណាដែលឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្តល់ ឬ (ចេញអោយ) ក្នុងទំរង់អាចចរចាបាន ទៅអោយបុគ្គលដែលមានឈ្មោះកំណត់ណាមួយ ដែលជាបុគ្គលមានភ័ស្តុតាងបញ្ជាក់ពីអត្តសញ្ញាណរបស់គាត់ និងមានកាន់ជាប់ឯកសារដើម ០១ ច្បាប់ ។ ប្រសិនបើឯកសារបែបនេះត្រូវបានផ្ទេរ "តាមការបញ្ជា" ឬប្រសិនបើទុកចំហ នោះបទប្បញ្ញត្តិនៃចំណុច " ខ " ខាងលើត្រូវបានគេយកមកអនុវត្ត ឬ

ឃ- នៅពេលណាដែលឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្តល់ ក្នុងទំរង់មិនអាចចរចាបានទៅអោយបុគ្គលកំណត់ឈ្មោះថា ជាអ្នកទទួលទំនិញនៅក្នុងឯកសារដោយមានភ័ស្តុតាងបញ្ជាក់អត្តសញ្ញាណរបស់គាត់ ឬ

ង- នៅពេលណាដែលគ្មានឯកសារណាមួយត្រូវបានផ្តល់ទៅអោយបុគ្គល ដូចបានណែនាំដោយអ្នកប្រគល់ទំនិញ ឬ ដោយបុគ្គលដែលបានទទួលសិទ្ធិពីអ្នកប្រគល់ទំនិញ ឬ អ្នកទទួលទំនិញ ដែលស្ថិតនៅក្រោមកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពក្នុងការផ្តល់ការណែនាំដូចនោះ ។

មាត្រា ១០

១- ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ត្រូវទទួលខុសត្រូវលើការបាត់បង់បណ្តាលមកពីការបាត់បង់ទំនិញព្រមទាំងការបាត់បង់បណ្តាលមកពីការយឺតយ៉ាវក្នុងការចែកចាយទំនិញ ប្រសិនបើជាហេតុការណ៍ដែលបណ្តាលអោយមានការខូចខាត បាត់បង់ ឬ យឺតយ៉ាវក្នុងការប្រគល់ទំនិញបានកើតឡើង នៅពេលដែលទំនិញនៅក្នុងបន្ទុកទទួលខុសត្រូវរបស់ប្រតិបត្តិករ ដូចបានចែងក្នុងមាត្រា ៧ លើកលែងតែប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពមានភ័ស្តុតាងបញ្ជាក់ថាខ្លួនគាត់ជាឬអ្នកបំរើរបស់គាត់ ភ្នាក់ងាររបស់គាត់ ឬ របស់បុគ្គលផ្សេងណាមួយ ដូចបានចែងក្នុងមាត្រា ៨ ដែលបានចាត់វិធានការទាំងអស់ ដែលអាចជាតំរូវការដ៏សមហេតុផលរបស់គាត់ ដើម្បីបញ្ចៀសឧបត្តិហេតុដែលបានកើតឡើង និងផលវិបាករបស់វា ។

២- ជាយ៉ាងណាក៏ដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព នឹងមិនទទួលខុសត្រូវចំពោះការបាត់បង់បណ្តាលមកពីការយឺតយ៉ាវក្នុងការប្រគល់ទំនិញ លើកលែងតែម្ចាស់ទំនិញបានធ្វើសេចក្តីប្រកាសនៃការចាប់អារម្មណ៍ (សេចក្តីប្រកាសទទួលស្គាល់) ក្នុងពេលប្រគល់ទំនិញដែលបានយល់ព្រមដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ។

មាត្រា ១១

១- ការយឺតយ៉ាវក្នុងការប្រគល់ទំនិញដែលបានកើតឡើង នៅពេលណាដែលទំនិញមិនត្រូវបានប្រគល់ក្នុងរយៈពេលដែលបានឯកភាពគ្នាយ៉ាងជាក់លាក់ ឬ ក្នុងករណីគ្មានការព្រមព្រៀងបែបនេះ វាគួរតែមានរយៈពេលមួយសមរម្យ ដែលជាការតំរូវសំរាប់ការយកចិត្តទុកដាក់របស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពមួយ ត្រូវបានពិចារណាដោយផ្អែកទៅលើកាលៈទេសៈនៃករណីនីមួយៗ ។

២- បើសិនជាទំនិញមិនបានប្រគល់ក្នុងរយៈពេល៩០ថ្ងៃជាប់គ្នាក្រោយកាលបរិច្ឆេទ នៃការប្រគល់ទំនិញកំណត់ឡើងដោយអនុលោមតាមវាក្យខ័ណ្ឌខាងដើម បុគ្គលណាក៏ដោយដែលគេបានផ្តល់សិទ្ធិក្នុងការតវ៉ាអំពីទំនិញក្នុងករណីគ្មានភ័ស្តុតាងបញ្ជាក់ផ្ទុយពីនេះ អាចចាត់ទុកថាទំនិញត្រូវបានបាត់បង់ ។

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

មាត្រា ១២

ថ្វីបើមានបទប្បញ្ញត្តិចែងក្នុងមាត្រា ១០ ក៏ដោយក៏ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព និងមិនទទួលខុសត្រូវក្នុងការបាត់បង់ការខូចខាតបាក់បែក ឬការយឺតយ៉ាវក្នុងការប្រគល់ទំនិញ ទៅលើទំនិញផ្សេងៗក្នុងការដឹកជញ្ជូនឡើយ ប្រសិនបើប្រតិបត្តិករនោះមានភស្តុតាងបញ្ជាក់ថា ព្រឹត្តិការណ៍ដែលបណ្តាលអោយមានការបាត់បង់ ខូចខាត ឬយឺតយ៉ាវបែបនេះបានកើតឡើងនៅក្នុងពេលដឹកជញ្ជូនស្របទៅតាមព្រឹត្តិការណ៍ ឬ កាលៈទេសៈមួយ ឬ ច្រើនដូចខាងក្រោម :

ក- ប្រធានស័ក្តិ

ខ- សកម្មភាពអំពើ ឬ ការធ្វេសប្រហែសរបស់អ្នកផ្តល់ទំនិញ អ្នកទទួលទំនិញ ឬ ក៏អ្នកតំណាង ឬ ភ្នាក់ងាររបស់គេ

គ- ការវេចខ្ចប់ ការដាក់សញ្ញា ឬការបង់លេខទំនិញមិនបានគ្រប់គ្រាន់ ឬត្រឹមត្រូវ

ឃ- ការលើក ការផ្ទុក ការផ្ទេរចេញ ការរៀបចំទុកដាក់ទំនិញ ធ្វើឡើងដោយអ្នកប្រគល់ទំនិញ (ម្ចាស់ទំនិញ) អ្នកទទួល ឬក៏អ្នកតំណាង ឬ ភ្នាក់ងាររបស់គេ

ង- ការខ្វះចន្លោះ លក្ខណៈជាប់ខាងក្រៅ (លក្ខណៈធម្មជាតិ) និងលក្ខណៈខាងក្នុងដែលមើលទំនិញមិនឃើញ

ច- កូដកម្ម ការបិទរោងចក្រ ការឈប់ធ្វើការងារ ការរឹតទាំងស្រុង ឬមួយផ្នែកលើការងារ

ឆ- អនុលោមទៅតាមទំនិញ ដែលដឹកជញ្ជូនតាមសមុទ្រ ឬផ្លូវទន្លេខាងក្នុងប្រទេស នៅពេលដែលការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវទាំងនោះ នៅក្នុងអំឡុងពេលដែលការដឹកជញ្ជូនបានកើតឡើងក្នុងករណីដូចខាងក្រោម :

១- អំពើ ឬ (សកម្មភាព) ការធ្វេសប្រហែស ឬក៏កំហុសឆ្គងនៃមេការ (មេបញ្ជាការ) នាវិក ពីឡុតនាវា ឬអ្នកបំរើ របស់អ្នកដឹកជញ្ជូនក្នុងពេលធ្វើនាវាចរ ឬនៅក្នុងពេលចាត់ចែងគ្រប់គ្រងនាវា ឬ

២- អគ្គីភ័យ លើកលែងតែករណីកើតឡើងជាក់ស្តែង ឬជារឿងផ្ទាល់ខ្លួនរបស់អ្នកដឹកជញ្ជូន ។ ទោះយ៉ាងណាក៏ដោយ ជានិច្ចជាកាលចែងថា នៅពេលដែលការបាត់បង់ ការខូចខាតគឺជាលទ្ធផលអំពីភាពមិនគ្រប់លក្ខណៈបច្ចេកទេសនៃនាវានោះ ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពអាចបង្ហាញភ័ស្តុតាងថា ក្នុងពេលដែលមានការប្រឹងប្រែងយកចិត្តទុកដាក់ត្រូវបានធ្វើឡើងដើម្បីអោយនាវាមានលក្ខណៈបច្ចេកទេសសមស្របនៅពេលចាប់ផ្តើម នៃការចេញដំណើរ ។

មាត្រា ១៣

១- ការវាយតំលៃនៃការចេញសងលើការបាត់បង់ ឬការខូចខាតដល់ទំនិញត្រូវធ្វើឡើងដោយផ្អែកលើតំលៃ នៃទំនិញទាំងនោះនៅនិងទីកន្លែង និងនៅក្នុងពេលវេលាដែលទំនិញត្រូវបានប្រគល់ទៅអោយអ្នកទទួលទំនិញ ឬ នៅនិងទីកន្លែង និងនៅពេលវេលាដែលទំនិញត្រូវប្រគល់ អនុលោមតាមកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព ។

២- តំលៃទំនិញនឹងត្រូវកំណត់ យោងតាមថ្លៃផ្លាស់ប្តូរផលិតផលថ្មីៗ ក្នុងបច្ចុប្បន្ន ឬ ប្រសិនបើគ្មានថ្លៃបែបនេះទេត្រូវយោងទៅតាមថ្លៃទីផ្សារបច្ចុប្បន្ន ឬ បើគ្មានថ្លៃទាំងពីរខាងលើទេ តំលៃផ្លាស់ប្តូរផលិតផល ឬ តំលៃទីផ្សារបច្ចុប្បន្នត្រូវយោងតំលៃទំនិញធម្មតាដែលមានប្រភេទ និង គុណភាពដូចគ្នា ។

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

ជំពូកទី ៥
ដែនកំណត់នៃការទទួលខុសត្រូវរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព

មាត្រា ១៤

លុះត្រាតែប្រភេទ និងតំលៃនៃទំនិញត្រូវបានប្រកាសដោយអ្នកប្រគល់ទំនិញនៅមុនពេលទំនិញត្រូវបានទទួលផ្ទុកដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព និងត្រូវបានបញ្ចូលទៅក្នុងឯកសារដឹកជញ្ជូនពហុរូបភាព ទើបប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ត្រូវបានក្លាយទៅជាអ្នកទទួលខុសត្រូវចំពោះការបាត់បង់ ឬ ការខូចខាតដល់ទំនិញក្នុងទឹកប្រាក់លើសពីចំនួនទឹកប្រាក់សមមូលនិង 666.67 SDR ក្នុងមួយកញ្ចប់ ឬ ឯកតា ឬ 2.00 SDR ក្នុងមួយគីឡូក្រាមនៃទំងន់ទាំងសំបក (ទំងន់សរុប) នៃទំនិញបាត់បង់ ឬ ខូចខាតលើទំនិញណាមួយក៏ដោយដែលមានតំលៃខ្ពស់ជាងគេ ។

មាត្រា ១៥

នៅពេលណាដែលមានកុងតែន័រ ប៉ាឡែត ឬ បន្ទុកដឹកជញ្ជូនប្រហាក់ប្រហែលណាមួយ ត្រូវបានគេផ្ទុកច្រើនជាងមួយកញ្ចប់ ឬមួយឯកតា បណ្តាកញ្ចប់ ឬឯកតាផ្ទុកផ្សេងៗទៀត ដែលរៀបរាប់នៅក្នុងឯកសារដឹកជញ្ជូនពហុរូបភាព ដូចដែលបានខ្ចប់នៅក្នុងបន្ទុកដឹកជញ្ជូនបែបនេះ នឹងត្រូវចាត់ជាកញ្ចប់ច្រើន ឬឯកតាផ្ទុកច្រើន ។ លើកលែងការរៀបរាប់រួចមកហើយនេះ បន្ទុកដឹកជញ្ជូនបែបនេះ នឹងត្រូវចាត់ជាកញ្ចប់ ឬឯកតាមួយ ។

មាត្រា ១៦

ថ្វីត្បិតតែមានបទប្បញ្ញត្តិចែងក្នុងមាត្រាទី ១៤ និង ១៥ ក៏ដោយ ដោយអនុលោមទៅតាមកិច្ចសន្យាប្រសិនបើការធ្វើដឹកជញ្ជូនពហុរូបភាព មិនបានរាប់បញ្ចូលការដឹកជញ្ជូនទំនិញតាមសមុទ្រ ឬតាមផ្លូវទឹកក្នុងប្រទេស ការទទួលខុសត្រូវរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ត្រូវកំរិតត្រឹមទឹកប្រាក់មិនលើស 8.33 SDR ក្នុងមួយគីឡូក្រាមទំងន់ទាំងសំបក (ទំងន់សរុប) នៃទំនិញដែលបាត់បង់ ឬ ខូចខាត ។

មាត្រា ១៧

នៅពេលណាដែលការបាត់បង់ ឬការខូចខាតដល់ទំនិញបានកើតមានឡើងក្នុងដំណាក់កាលពិសេសដោយឡែកណាមួយនៃការដឹកជញ្ជូនពហុរូបភាពដោយអនុលោមទៅតាមអនុសញ្ញាអន្តរជាតិ ឬ ច្បាប់ជាបាច់ដែលកំពុងអនុវត្តដែលមានចែងកំរិតទទួលខុសត្រូវផ្សេងៗទៀត និងប្រសិនបើកិច្ចសន្យាដឹកជញ្ជូនដាច់ដោយឡែកមួយ ត្រូវបានរៀបចំឡើងសំរាប់ដំណាក់កាលដឹកជញ្ជូនដាច់ដោយឡែកនេះ នោះកំរិតនៃការទទួលខុសត្រូវរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពចំពោះការបាត់បង់ ឬការខូចខាតបែបនេះនឹងត្រូវកំណត់ដោយយោងទៅតាមបទប្បញ្ញត្តិនៃអនុសញ្ញា ឬច្បាប់ចាំបាច់ទាំងនោះ ។

មាត្រា ១៨

ប្រសិនបើប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ត្រូវទទួលខុសត្រូវចំពោះការបាត់បង់បណ្តាលមកពីការយឺតយ៉ាវក្នុងការប្រគល់ឬការបាត់បង់ ឬការខូចខាតផ្សេងទៀតជាផលវិបាកក្រៅពីការបាត់បង់ ឬខូចខាតទំនិញ ការទទួលខុសត្រូវរបស់ប្រតិបត្តិករនឹងត្រូវកំណត់ត្រឹមទឹកប្រាក់មួយចំនួនមិនលើសពីតំលៃសមមូល នៃទំនិញនៅក្រោមកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពសំរាប់ការដឹកជញ្ជូនពហុរូបភាព ។

មាត្រា ១៩

ការទទួលខុសត្រូវមួយផ្នែកៗរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព មិនត្រូវលើសកំរិតទទួលខុសត្រូវលើការបាត់បង់ទំនិញទាំងស្រុងឡើយ ។

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

មាត្រា ២០

ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពគ្មានសិទ្ធិទទួលអត្ថប្រយោជន៍ពីការកំណត់ព្រំដែន នៃការទទួលខុសត្រូវ ប្រសិនបើគេមានភស្តុតាងបញ្ជាក់ថា ការបាត់បង់ការខូចខាត ឬការយឺតយ៉ាវក្នុងការប្រគល់ទំនិញបណ្តាលមកពីអំពើផ្ទាល់ខ្លួនណាមួយ ឬការខ្វះខាតរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ធ្វើឡើងក្នុងបំណងចេតនាបណ្តាលអោយមានការបាត់បង់ ការខូចខាត ឬ ការយឺតយ៉ាវបែបនេះ ឬដោយមិនប្រុងប្រយ័ត្ន និងដោយដឹងថាការបាត់បង់ការខូចខាតអាចនឹងកើតមានឡើង ។

ជំពូកទី ៦
ការទទួលខុសត្រូវរបស់អ្នកប្រគល់ទំនិញ

មាត្រា ២១

១- អ្នកប្រគល់ទំនិញនឹងត្រូវចាត់ថា មានការធានាក៏បរងចំពោះប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពនូវភាពត្រឹមត្រូវនៃទំនិញ នៅក្នុងពេលដែលទំនិញត្រូវបានគេប្រគល់អោយ និងទទួលយកដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពនូវរាល់ចំណុចពិសេសពាក់ព័ន្ធដល់ប្រភេទទូទៅនៃទំនិញ សញ្ញាសំគាល់លេខរៀង ទំងន់ ទំហំ និងបរិមាណ និងបើអាចអនុវត្តបានលក្ខណៈគ្រោះថ្នាក់នៃទំនិញផ្តល់ដោយខ្លួនគេ ឬ ក្នុងនាមខ្លួនដើម្បីបញ្ចូលទៅក្នុងឯកសារដឹកជញ្ជូនពហុរូបភាព ។

២- អ្នកប្រគល់ទំនិញត្រូវដាក់សញ្ញា ឬ ដាក់ផ្លាកទំនិញគ្រោះថ្នាក់ ដោយអនុលោមតាមអនុសញ្ញាអន្តរជាតិ ឬច្បាប់ជាតិណាមួយដែលអាចអនុវត្តបានដែរ ។

៣- នៅក្នុងកន្លែងដែលអ្នកប្រគល់ទំនិញ ប្រគល់ទំនិញគ្រោះថ្នាក់ទៅអោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ឬបុគ្គលណាមួយទៀតដែលធ្វើសកម្មភាពក្នុងនាមខ្លួន អ្នកប្រគល់ទំនិញត្រូវជូនដំណឹងដល់ប្រតិបត្តិករ ឬ បុគ្គលនោះនូវលក្ខណៈគ្រោះថ្នាក់នៃទំនិញនឹងប្រសិនបើចាំបាច់ត្រូវប្រកាសអោយប្រតិបត្តិករប្រកាន់យកនូវការព្រមានជាមុន ។ បើសិនជាអ្នកប្រគល់ទំនិញខកខានមិនបានធ្វើដូចនេះ ហើយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពមិនបានដឹងពីវេតគ្រោះថ្នាក់នៃទំនិញតាមផ្លូវផ្សេងទៀត :

- ក- អ្នកប្រគល់ទំនិញត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពដល់ការបាត់បង់ដែលបណ្តាលមកពីការផ្ទុកទំនិញបែបនេះ
- ខ- នៅពេលណាមួយក៏ដោយទំនិញអាចរើចេញបំផ្លាញ ឬ ធ្វើអោយលែងមានគ្រោះថ្នាក់ទៅតាមកាលៈទេសៈតំរូវដោយគ្មានការទូទាត់ជាសំណងឡើយ

៤- បទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ ៣ របស់មាត្រានេះ ពុំអាចផ្តើមឡើងយកមកប្រើដោយបុគ្គលណាមួយបានឡើយ បើសិនជាក្នុងរយៈពេលដឹកជញ្ជូន បុគ្គលនោះបានទទួលបន្ទុកទំនិញដោយបានដឹងពីលក្ខណៈគ្រោះថ្នាក់នៃទំនិញជាមុន ។

៥- ក្នុងករណីបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ ៣-ខ នៃមាត្រានេះមិនបានអនុវត្ត ឬ មិនយកមកប្រើ ប្រសិនបើទំនិញគ្រោះថ្នាក់ក្លាយជាគ្រោះថ្នាក់ពិតមែនដល់អាយុជីវិត ឬទ្រព្យសម្បត្តិ នោះទំនិញអាចត្រូវរើចេញ ឬបំផ្លាញ ឬធ្វើអោយលែងមានគ្រោះថ្នាក់ ទៅតាមកាលៈទេសៈតំរូវដោយគ្មានទូទាត់ លើកលែងតែនៅពេលណាដែលវាត្រូវមានកាតព្វកិច្ចណាមួយរួមចំណែកក្នុងមធ្យមភាគជាទូទៅ ឬ លើកលែងតែប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ត្រូវទទួលខុសត្រូវដោយអនុលោមទៅតាមមាត្រាទី ១០ និង ទី ១១ ។

៦- អ្នកប្រគល់ទំនិញត្រូវសងប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ចំពោះការបាត់បង់បណ្តាលមកពីភាពមិនត្រឹមត្រូវ ឬភាព មិនគ្រប់គ្រាន់ នៃចំណុចពិសេស ដូចមានយោងក្នុងវាក្យខ័ណ្ឌខាងដើម ។

៧- អ្នកប្រគល់ទំនិញនៅតែត្រូវទទួលខុសត្រូវ ថ្វីបើឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្ទេរពីខ្លួនក៏ដោយ ។

៨- សិទ្ធិនៃប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពទៅលើសំណងបែបនេះ នឹងមិនមានករណីណាមួយដែលកំរិតការទទួលខុសត្រូវរបស់ខ្លួន ក្រោមកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព ចំពោះបុគ្គលណាមួយក្រៅពីអ្នកប្រគល់ទំនិញឡើយ ។

ជំពូកទី ៧
ការតវ៉ា ការប្តឹង និងអាជ្ញាយុកាល
មាត្រា ២២

១- លុះត្រាតែមានការកត់ត្រា ឬប្រកាសពីការបាត់បង់ ឬ ខូចខាតនៃទំនិញដែលបញ្ជាក់ពីទិដ្ឋភាពទូទៅ នៃការបាត់បង់ ឬ ខូចខាតត្រូវបានផ្តល់ជាលាយល័ក្ខអក្សរ ដោយអ្នកទទួលទំនិញទៅអោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពនៅពេលដែលទំនិញត្រូវបានប្រគល់ទៅអោយអ្នកទទួលទំនិញ ហើយការប្រគល់បែបនេះជាភ័ស្តុតាងលើកដំបូងបំផុតនៃការប្រគល់ទំនិញដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ដូចដែលបានរៀបរាប់ក្នុងឯកសារដឹកជញ្ជូនពហុរូបភាព ។

២- នៅពេលណាដែលការបាត់បង់ ឬ ខូចខាតមិនបានសំដែងឡើងច្បាស់លាស់ ឥទ្ធិពលដូចគ្នានៃភ័ស្តុតាងដំបូងបំផុតត្រូវបានអនុវត្ត ប្រសិនបើកាប្រកាសជាលាយល័ក្ខអក្សរមិនត្រូវបានផ្តល់ក្នុងរយៈពេល៦ថ្ងៃជាប់គ្នា បន្ទាប់ពីថ្ងៃដែលទំនិញត្រូវបានប្រគល់ទៅអោយអ្នកទទួលទំនិញ ។

មាត្រា ២៣

លើកលែងតែបានព្រមព្រៀងគ្នាជាក់លាក់ផ្សេងពីនេះ អំពើណាមួយដែលពាក់ពន្ធ័ដល់ការដឹកជញ្ជូនពហុរូបភាពក្រោមកិច្ចព្រមព្រៀងនេះនឹងត្រូវបានអាជ្ញាយុកាល លើកលែងតែពេលណានិតិវិធីបណ្តឹងតុលាការ ឬអាជ្ញាកណ្តាលបានចាប់ផ្តើមក្នុងរយៈពេល ៩ ខែ ក្រោយការប្រគល់ទំនិញ ឬប្រសិនជាទំនិញមិនបានប្រគល់ក្រោយកាលបរិច្ឆេទ ដែលទំនិញត្រូវប្រគល់ ឬ ក្រោយកាលបរិច្ឆេទដែលអនុលោមទៅតាមបទប្បញ្ញត្តិចែងក្នុងមាត្រា ១១ វាក្យខ័ណ្ឌ ២ នោះការខកខានក្នុងការប្រគល់ទំនិញ នឹងផ្តល់សិទ្ធិអោយទៅអ្នកទទួលទំនិញក្នុងការចាត់ទុកទំនិញថាបានបាត់បង់ ។

មាត្រា ២៤

១- បទប្បញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងអនុវត្តទៅលើរាល់ការតវ៉ាទល់នឹងប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពដែលពាក់ព័ន្ធដល់ការអនុវត្តន៍កិច្ចសន្យាដឹកជញ្ជូនពហុរូបភាព នៅពេលណាដែលការតវ៉ាមាននៅក្នុងកិច្ចសន្យា ឬ ក្នុងអ្វីៗដែលប្រឆាំងនឹងច្បាប់ ។

២- ប្រហាក់ប្រហែលគ្នានេះដែរបទប្បញ្ញត្តិ នឹងត្រូវអនុវត្តពេលណាដែលការតវ៉ាពាក់ព័ន្ធដល់ការអនុវត្តន៍កិច្ចសន្យាដឹកជញ្ជូនពហុរូបភាពត្រូវបានធ្វើឡើងទល់នឹងអ្នកបំរើ ឬ ភ្នាក់ងារ បុគ្គលណាម្នាក់ ដែលសេវាកម្មរបស់គាត់ត្រូវបានប្រើដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ដើម្បីអនុវត្តកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព ទោះការតវ៉ាបែបនេះត្រូវបានរកឃើញក្នុង កិច្ចសន្យា ឬ អ្វីប្រឆាំងនឹងច្បាប់ ហើយការទទួលខុសត្រូវជាផ្នែក១ នៃប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព និងអ្នកបំរើ ភ្នាក់ងារ ឬ បុគ្គលផ្សេងទៀតនឹងមិនលើសពីការកំណត់នៅក្នុងមាត្រា ទី ១៤ ដល់ ១៩ ។

៣- ថ្វីបើមានវាក្យខ័ណ្ឌ ២ ភ្នាក់ងា ឬ អ្នកបំរើម្នាក់ នៃប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ឬ បុគ្គលផ្សេងទៀតដែលធ្វើសេវារបស់គេទាំងនោះ ដែលគាត់ប្រើសំរាប់អនុវត្តកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព គឺគ្មានសិទ្ធិទទួលផលប្រយោជន៍ពីការកំណត់ ព្រំដែននៃការទទួលខុសត្រូវ ប្រសិនបើមានភ័ស្តុតាងបញ្ជាក់នូវការបាត់បង់ ខូចខាត ឬការយឺតយ៉ាវក្នុងការប្រគល់ទំនិញ ដែលជាលទ្ធផលមកពីការបំភ្លេចចោលដោយសកម្មភាពផ្ទាល់ខ្លួន ឬការធ្វេសប្រហែសនៃអ្នកបំរើ ឬភ្នាក់ងារ ឬមនុស្សដ៏ទៃទៀត ដែលធ្វើដោយចេតនា ដើម្បីបណ្តាលអោយមានការបាត់បង់ បាក់បែក ឬយឺតយ៉ាវ ឬការមិនប្រយ័ត្នប្រយែង និងដោយទទួលស្គាល់ ឬដឹងថាការបាត់បង់ បាក់បែក ឬការយឺតយ៉ាវអាចនឹងកើតមានឡើង ។

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

ជំពូកទី ៨
យុត្តាធិការ និងសមត្ថកិច្ច
មាត្រា ២៥

១- ក្នុងនីតិវិធីបណ្តឹងតុលាការពាក់ព័ន្ធដល់ការដឹកជញ្ជូនពហុរូបភាពអន្តរជាតិ ដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ ដើមក្តីតាមការជ្រើសរើសរបស់ខ្លួនផ្ទាល់ អាចធ្វើបណ្តឹងមួយទៅតុលាការមានសមត្ថកិច្ច អនុលោមតាមច្បាប់នៃប្រទេសដែលតុលាការស្ថិតនៅក្របខ័ណ្ឌយុត្តាធិការទីកន្លែងមួយ នៃទីកន្លែងដូចខាងក្រោមនេះស្ថិតនៅ :

ក- ទីកន្លែងគោលសំខាន់នៃពាណិជ្ជកម្ម ឬ បើគ្មានទេ និវេសនដ្ឋានជាទំលាប់នៃចុងចោទ ឬ

ខ- ទីកន្លែងដែលកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពត្រូវបានធ្វើឡើង ដែលចែងថា ចុងចោទមាននៅទីនោះនូវកន្លែងធ្វើពាណិជ្ជកម្ម សាខា ទីភ្នាក់ងារតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង ។ ឬ

គ- ទីកន្លែងទទួល(ផ្ទុក)ទំនិញ សំរាប់ការងារដឹកជញ្ជូនពហុរូបភាព ឬទីកន្លែងចែកចាយ ឬ

ឃ- ទីកន្លែងផ្សេងទៀតណាមួយដែលបានកំណត់សំរាប់គោលបំណងនេះ ក្នុងកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព និងមានបញ្ជាក់នៅក្នុងឯកសារដឹកជញ្ជូនពហុរូបភាព ។

២-ទោះមិនយោងទៅលើបទប្បញ្ញត្តិដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះក៏ដោយ ការព្រមព្រៀងដោយគូភាគីក្រោយពីការតវ៉ាបានកើតមានឡើង ដែលបានកំណត់ទីកន្លែងណាដែលដើមចោទអាចប្តឹងតវ៉ា ត្រូវតែមានប្រសិទ្ធិភាព ។

មាត្រា ២៦

១- ជាកម្មវត្ថុនៃបទប្បញ្ញត្តិរបស់មាត្រានេះ គូភាគីអាចចែងដោយការព្រមព្រៀងបញ្ជាក់ជាលាយល័ក្ខអក្សរថា ជំលោះណាក៏ដោយដែលអាចកើតមានឡើងពាក់ព័ន្ធដល់ការដឹកជញ្ជូនពហុរូបភាពជាអន្តរជាតិក្រោមកិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយដោយអាជ្ញាកណ្តាល (មជ្ឈត្តកម្ម) ។

២- បណ្តឹងអាជ្ញាកណ្តាល (បណ្តឹងមជ្ឈត្តកម្ម) ត្រូវធ្វើឡើងតាមការជ្រើសរើសរបស់ដើមចោទនៅទីកន្លែងមួយក្នុងចំណោមទីកន្លែងដូចខាងក្រោម :

ក- ទីកន្លែងមួយនៅក្នុងប្រទេស ដែលជាដែនដីនៃនរណាម្នាក់បានស្ថិតនៅ :

១- ទីកន្លែងជាមូលដ្ឋានធ្វើពាណិជ្ជកម្មរបស់ចុងចោទ ឬបើគ្មានទេ ដូចនេះនិវេសនដ្ឋានរស់នៅជាទំលាប់របស់ចុងចោទ ឬ

២- ទីកន្លែងធ្វើកិច្ចសន្យាពហុដឹកជញ្ជូនមានន័យថា ដែលចុងចោទមាននៅទីនោះនូវទីកន្លែងសំរាប់បំពេញការងារ ឬ សាខា ឬ ទីភ្នាក់ងារដែលតាមរយៈនោះកិច្ចសន្យាបានត្រូវធ្វើឡើង ឬ

៣- ទីកន្លែងទទួលផ្ទុកទំនិញសំរាប់ការដឹកជញ្ជូនពហុរូបភាពជាអន្តរជាតិ ឬ ទីកន្លែងចែកចាយទំនិញ

ខ- ទីកន្លែងផ្សេងណាមួយដែលកំណត់សំរាប់សំណូមពរនេះ ដែលមាននៅក្នុងប្បញ្ញត្តិអាជ្ញាកណ្តាល (ការវិនិច្ឆ័យដោយអាជ្ញាកណ្តាល) ឬ ដោយការព្រមព្រៀង ។

៣- អ្នកអាជ្ញាកណ្តាល ឬតុលាការអាជ្ញាកណ្តាល ត្រូវអនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ។

៤- បទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ ២ និង ៣ នៃមាត្រានេះ នឹងចាត់ទុកជាផ្នែកមួយនៃរាល់មជ្ឈត្តវិនិច្ឆ័យ (ការវិនិច្ឆ័យដោយអជ្ញាកណ្តាល) ឬ ការព្រមព្រៀង ។ ល័ក្ខខ័ណ្ឌណាមួយនៃប្បញ្ញត្តិទាំងនេះ ឬការព្រមព្រៀងដែលមិនសមស្របតាមនេះនឹងទុកជាមោឃៈ ។

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

៥- គ្មានអ្វីនៅក្នុងប្រការនេះនឹងត្រូវប៉ះពាល់ដល់សុពលភាពនៃការព្រមព្រៀងលើអាជ្ញាកណ្តាល ដែលធ្វើដោយភាគីទាំងឡាយនៅក្រោយការតវ៉ាពាក់ព័ន្ធដល់ការដឹកជញ្ជូនពហុរូបភាពអន្តរជាតិត្រូវបានលើកឡើងទេ ។

មាត្រា ២៧

១- ការចែងណាមួយក្នុងឯកសារពហុរូបភាពនឹងទៅជាមោឃៈ និងអាសារឥតការ និងមិនមានឥទ្ធិពលទាំងអស់ ប្រសិនបើការចែងនោះ ឬមួយចេញដោយផ្ទាល់ ឬ ដោយប្រយោលពីបទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ និងជាពិសេស ប្រសិនបើការចែងទាំងឡាយ ត្រូវបានគេធ្វើឡើងប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកផ្តល់ទំនិញ ឬអ្នកទទួលទំនិញ ។ ការចែងនេះ ក៏នឹងមិនប៉ះពាល់ដល់មាត្រាផ្សេងទៀតដែលមាននៅក្នុងឯកសារនោះ ។

២- ទោះបីជាមានបទប្បញ្ញត្តិដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះក៏ដោយ ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពដោយមានការអនុញ្ញាតពីម្ចាស់ទំនិញ អាចបង្កើននូវការទទួលខុសត្រូវ និងកាតព្វកិច្ចទាំងឡាយរបស់គេនៅក្រោមកិច្ចព្រមព្រៀងនេះបាន ។

មាត្រា ២៨

បទប្បញ្ញត្តិនៃសេចក្តីភ្ជាប់នេះ នឹងមិនបង្អាក់ដល់ដំណើរការអនុវត្តនីតិវិធានការទាំងឡាយ ពាក់ព័ន្ធដល់ការតំរូវមធ្យមភាគទូទៅដែលមាននៅក្នុងកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព ឬ នៅក្នុងច្បាប់ជាតិដែលពាក់ព័ន្ធ ដែលសំដែងឡើងក្នុងកំរិតដែលអាចអនុវត្តបាន ។

(តទៅរាជកិច្ចលេខ ៩៣)

ព្រះរាជក្រឹត្យ

នស/រកត/១២០៦/៤៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **សុខ ចមឆាន់ឫទ្ធី** ពីជំនួយការឯកឧត្តម **លី ឡាយស្រេង** ឧបនាយករដ្ឋមន្ត្រី ។

មាត្រា២: ត្រូវបានតែងតាំងឯកឧត្តម **សួង សុខេន** ជាជំនួយការ ឯកឧត្តម **លី ឡាយស្រេង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក** ជំនួស ឯកឧត្តម **សុខ ចមឆាន់ឫទ្ធី** ដែលបានបញ្ចប់មុខតំណែង ។

មាត្រា៣: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ២០០៦

ឡូវព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

ត.រ.ល.០៦១២.៥១១ លេខ: ៤៥៧ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ខែ ធ្នូ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៦/៨៤៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ .- ត្រូវបានតម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់របស់ក្រសួងសុខាភិបាល គិតចាប់ពី ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ នេះតទៅ នូវមន្ត្រីរាជការស៊ីវិល ដូចមានរាយនាមខាងក្រោម ÷

១	សាស្ត្រាចារ្យ ហេង តៃត្រី	ប្រុស	ពីថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
២	សាស្ត្រាចារ្យ យក់ សុផាន់ណា	ប្រុស	ពីថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៣	សាស្ត្រាចារ្យ ឆា សុខអេង	ស្រី	ពីថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៤	សាស្ត្រាចារ្យ ជ័យ ទិត្យា	ប្រុស	ពីថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៥	សាស្ត្រាចារ្យ ឈួ អ៊ីម៉េង	ប្រុស	ពីថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៦	សាស្ត្រាចារ្យ កើត មៀច	ប្រុស	ពីថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៧	សាស្ត្រាចារ្យ ម៉េង ថៃ	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៨	សាស្ត្រាចារ្យ យឹត ស៊ីនណារ៉ា	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៩	សាស្ត្រាចារ្យ ប្រាក់ សេងហួ	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១០	សាស្ត្រាចារ្យ តាន់ តឹកស្រេង	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១១	សាស្ត្រាចារ្យ ម៉ូ អ៊ាច	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១២	សាស្ត្រាចារ្យ ស៊ា ហួង	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១៣	សាស្ត្រាចារ្យ គុំ ភាណាល់	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១៤	សាស្ត្រាចារ្យ យ៉ាង យ៉ាណា	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១៥	សាស្ត្រាចារ្យ ឆា គ្រួយ	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១៦	សាស្ត្រាចារ្យ យួន ពីជិត	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១៧	សាស្ត្រាចារ្យ សៀង ថាវិទ្ធ	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១៨	សាស្ត្រាចារ្យ គ្រួយ លាងស៊ីម	ស្រី	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១៩	សាស្ត្រាចារ្យ តៅ ទាសនា	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២០	សាស្ត្រាចារ្យ នង នីមគី	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២១	សាស្ត្រាចារ្យ ឈួយ ម៉េង	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២២	សាស្ត្រាចារ្យ ការ ស៊ីនបូណាត	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២៣	សាស្ត្រាចារ្យ មុំ ដោត	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២៤	សាស្ត្រាចារ្យ ចាន់ រី	ស្រី	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២៥	សាស្ត្រាចារ្យ លៀង ចន្ទរិទ្ធ	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២៦	សាស្ត្រាចារ្យ សាន់ ចំន្ទសឿន	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២៧	សាស្ត្រាចារ្យ ហេង សម្បត្តិ	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២៨	សាស្ត្រាចារ្យ គេង សឿន	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
២៩	សាស្ត្រាចារ្យ អ៊ុង ចាន់នី	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥

៣០	សាស្ត្រាចារ្យ អ៊ឹម ជុំម	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៣១	សាស្ត្រាចារ្យ ស៊ឹម ម៉ុតសាគុណ	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៣២	សាស្ត្រាចារ្យ ចេង ស៊ុនគាំង	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៣៣	សាស្ត្រាចារ្យ សាន់ សុជីវី	ស្រី	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៣៤	សាស្ត្រាចារ្យ សួន ផានី	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៣៥	សាស្ត្រាចារ្យ ហែម ឈិន	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៣៦	សាស្ត្រាចារ្យ ឱុយ ធែល	ប្រុស	ពីថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥

មាត្រា ២ .- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស/រកត.១២០៦.៥១២

លេខ ៤៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៦/៤៨៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម គីម ឆា

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ២០០៦
ទូលព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

៣៧៧.០៦១២.៥១៣

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ : ៤៥៥ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១១៨/០១៨/២០០៦

ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦

សេចក្តីសម្រេច

លេខ : ០៨៩/០១៦/២០០៦ កបធ.ច

ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ
- បានឃើញលិខិតលេខ សធ/០៦/៩៩ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់តំណាងរាស្ត្រ ចំនួន ១៤ រូប ស្នើសូមពិនិត្យមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដើម្បីធ្វើការប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ០៩ : ៣០ នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា កម្មវត្ថុនៃលិខិតរបស់តំណាងរាស្ត្រ ចំនួន ១៤ រូប មានខ្លឹមសារបង្ហាប់បញ្ហា ពីព្រោះប្រើពាក្យថា " *សូមពិនិត្យមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដើម្បីធ្វើការប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ* "

- យល់ឃើញថា ការយោងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញនៅក្នុងលិខិតលេខ សធ/០៦/៩៩ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦របស់តំណាងរាស្ត្រ ចំនួន ១៤ រូប មិនត្រឹមត្រូវ ពីព្រោះច្បាប់ស្តីពីលក្ខន្តិកៈតំណាង-រាស្ត្រ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ រួចទៅហើយ
- យល់ឃើញថា ខ្លឹមសារនៃលិខិតលេខ សធ/០៦/៩៩ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់តំណាង-រាស្ត្រ ចំនួន ១៤ រូប បានថ្លែងថា *"...យើងខ្ញុំបានឃើញនូវចម្លើយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ ពាក់ព័ន្ធនឹងមាត្រា ៥ នៃច្បាប់នេះរួចហើយ ដោយក្រុមប្រឹក្សាធម្មនុញ្ញបានឆ្លើយបញ្ជាក់ថា មាត្រា ៥ នោះពុំមានអធម្មនុញ្ញភាពទេ។ យើងខ្ញុំមានការសោកស្តាយ ដែលក្រុមប្រឹក្សាពុំបានពិនិត្យនូវខ្លឹមសារនៃមាត្រា ៨ ផង ដែលមាត្រានេះបង្ហាញមិនអាចប្រកែកបាននូវអធម្មនុញ្ញភាព ។ព្រោះវាមានលក្ខណៈងាយយល់ជាង "* ។ ជាគោលការណ៍ និង តាមយុត្តិសាស្ត្ររបស់ខ្លួនតាំងពីឆ្នាំ១៩៩៨ មក ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកបញ្ហាណាមួយមកពិនិត្យដោយខ្លួនឯងបានឡើយ លុះត្រាតែមានការស្នើសុំពីឥស្សរជន ដូចមានចែងក្នុងមាត្រា ១៤០ ថ្មី មាត្រា ១៤១ ថ្មីវាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ឬ ប្រជារាស្ត្រដូចមានចែងក្នុងមាត្រា ១៤១ ថ្មីវាក្យខ័ណ្ឌទី២នៃរដ្ឋធម្មនុញ្ញ ទើបក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ
- យល់ឃើញថា ថ្វីបើមានបញ្ហាខ្លះ ក្រុមប្រឹក្សាធម្មនុញ្ញអាចយកសំណើរបស់តំណាងរាស្ត្រ ចំនួន ១៤ រូប មកពិនិត្យនៅក្នុងក្របខ័ណ្ឌនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨
- យល់ឃើញថា អភ័យឯកសិទ្ធិសភា មិនមែនជាឯកសិទ្ធិរបស់តំណាងរាស្ត្រទេ ប៉ុន្តែជាការធានាមួយផ្តល់ជូនរដ្ឋសភា ដើម្បីឱ្យការប្រព្រឹត្តទៅរបស់ខ្លួនមានប្រសិទ្ធភាពល្អ និង គ្មានឧបសគ្គ ។ ផ្តើមចេញពីអភ័យ-ឯកសិទ្ធិផ្តល់ជូនរដ្ឋសភានេះ សមាជិកម្នាក់ៗរបស់រដ្ឋសភាមិនត្រូវបានគេចោទប្រកាន់ ឃាត់ខ្លួន ចាប់ខ្លួន ឬ ឃុំខ្លួនជាដាច់ខាត ដោយសារការបញ្ចេញមតិ ឬ ការបោះឆ្នោតទាំងឡាយក្នុងពេលបំពេញមុខងាររបស់ខ្លួននៅរដ្ឋសភា ។ ប៉ុន្តែ ការរួចផុតពីការទទួលខុសត្រូវនេះ ក៏មានព្រំដែនកំណត់ដែរ គឺអំពើ ឬ សំដីខុសឆ្គងទាំងឡាយរបស់សមាជិករដ្ឋសភានឹងអាចត្រូវបានផ្តន្ទាទោសផ្នែកវិន័យដោយរដ្ឋសភា ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា
- យល់ឃើញថា ក្រៅពីពេលបំពេញមុខងាររបស់ខ្លួននៅរដ្ឋសភា តំណាងរាស្ត្រម្នាក់ៗនឹងអាចត្រូវបានគេចោទប្រកាន់ ឃាត់ខ្លួន ចាប់ខ្លួន ឬ ឃុំខ្លួនទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ គណៈ-កម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើស

ព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ជាបន្ទាន់ដើម្បីសម្រេច ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័ត

- យល់ឃើញថា ការសម្រេចព្យួរអភ័យឯកសិទ្ធិសភាពីតំណាងរាស្ត្រ ឬ ការសម្រេចប្រគល់ឱ្យវិញនូវអភ័យឯកសិទ្ធិសភាដល់តំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់រដ្ឋសភា
- យល់ឃើញថា បទបញ្ញត្តិក្នុងចំណុចទី ១ និង ចំណុចទី ២ នៃមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ មានចែងអំពីអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រ ដែលតាមការពិតជាអភ័យឯកសិទ្ធិរបស់រដ្ឋសភាទេ ។

សម្រេច

មាត្រា ១.- ផ្អែកតាមមូលបទខាងលើ មាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ ពុំមានអធម្មនុញ្ញភាពទេ ។

មាត្រា ២.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។៚

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

ស ម្រេ ច

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅបង្កើតមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយមចំណុះអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលរបស់ក្រសួងធនធានទឹក និងឧតុនិយមបំពេញបន្ថែមក្នុងរចនាសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងធនធានទឹក និងឧតុនិយម ។

មាត្រា ២.-

មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយមមានភារកិច្ចដូចតទៅ ÷

-សិក្សាតម្រូវការអភិវឌ្ឍធនធានមនុស្ស សម្រាប់វិស័យធនធានទឹក និងឧតុនិយម

-ធ្វើការបណ្តុះបណ្តាល និងវិក្រឹតការ ដល់មន្ត្រីបច្ចេកទេសទាំងថ្នាក់កណ្តាល និងខេត្ត-ក្រុង លើវិស័យធនធានទឹក និងឧតុនិយម

-សិក្សាស្រាវជ្រាវបច្ចេកវិទ្យាថ្មី និងធ្វើទំនើបកម្មលើប្រព័ន្ធធារាសាស្ត្រ

-ផ្សព្វផ្សាយនូវបច្ចេកវិទ្យាថ្មី និងទំនើបកម្មលើវិស័យធនធានទឹក និងឧតុនិយម

-រៀបចំចងក្រងឯកសារសៀវភៅបច្ចេកទេស និងព័ត៌មានដែលពាក់ព័ន្ធនឹងវិស័យធនធានទឹក និងឧតុនិយម

-ផ្តល់ការប្រឹក្សាបច្ចេកទេសទៅដល់មន្ត្រីបច្ចេកទេសមន្ទីរខេត្ត -ក្រុង និងការដ្ឋានសាងសង់ប្រព័ន្ធធារាសាស្ត្រ ឧតុនិយម

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

មាត្រា ៣.-

មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយមដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ថ្នាក់ការិយាល័យនៃមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ... ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១, , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ,បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ១៥៥ អនក្រ,បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១ : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន: ៣០០.០០០.០០០រៀល (បីរយលានរៀលគត់) ពីជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) មកជំពូក ៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា) ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយទូទាត់បំណុលឆ្នាំ ២០០៥ ជូនអង្គការ **FAO** និង វិភាគទានជូនអង្គការ **ITTO** ឆ្នាំ ២០០៦ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ–ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការលុបឋានានុក្រមអភិបាលរងទី១ខេត្ត ក្រុង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៦ ស្តីពី ការកំណត់តួនាទី និង ឋានានុក្រមអភិបាល អភិបាលរងខេត្ត ក្រុង
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ .-

ត្រូវបានលុប ឋានានុក្រមអភិបាលរងទី១ នៃរចនាសម្ព័ន្ធដឹកនាំខេត្ត ក្រុង ដោយរក្សាទុកអោយមានតែ អភិបាល និង អភិបាលរងខេត្ត ក្រុង។

មាត្រា២ .-

តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារ របស់អភិបាល និង អភិបាលរងខេត្ត ក្រុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា៣ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)

-ដូចមាត្រា ៤

(ដើម្បីអនុវត្ត)

-ឯកសារ កាលប្បវត្តិ

-រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៦៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានផ្លាស់លោក គីម សារិន បច្ចុប្បន្នជាទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម វិលចូលប្រទេសវិញ ។

មាត្រា ២ : ត្រូវបានតែងតាំងលោក សុខ សោភ័ណ បច្ចុប្បន្នជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ជំនួសលោក គីម សារិន ដែលបានផ្លាស់ឱ្យចូលប្រទេសវិញ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានផ្លាស់លោក ជា ម៉ារ៉ាត បច្ចុប្បន្នជាអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ រាជាណាចក្រថៃឡង់ដ៍ វិលចូលប្រទេសវិញ ។

មាត្រា ២ : ត្រូវបានតែងតាំងលោក នេត សេរី បច្ចុប្បន្នជាអនុប្រធាននាយកដ្ឋានអាស៊ីទី ១ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ រាជាណាចក្រថៃឡង់ដ៍ ជំនួសលោក ជា ម៉ារ៉ាត ដែលបានផ្លាស់ឱ្យចូលប្រទេសវិញ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៦៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក អេង ហ៊ិន បច្ចុប្បន្នជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុង ណាននីង ខេត្តស្វយ័តក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧៧ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការផ្លាស់ប្ដូរ និងបន្ថែមសមាសភាព អង្គភាពប្រឆាំងអំពើពុករលួយ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០០៦ ស្ដីពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ
- យោងតាមការចាំបាច់

សម្រេច

មាត្រា ១: ត្រូវបានបញ្ចូលឯកឧត្ដម **នុត សារអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ជំនួសឯកឧត្ដម **ទ្រី សុខា** ។

មាត្រា ២ : ត្រូវបានបន្ថែមឯកឧត្ដម **កុល ចិរត្ន** អគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ក្រសួងមហាផ្ទៃ ជាសមាជិកនៃអង្គភាពប្រឆាំងអំពើពុករលួយ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ អភិបាលខេត្ត ក្រុង និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- កាលប្បវត្តិ ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៤៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគ ធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តជ័យគីរី វត្តស្រក និងវត្តទួលរកា ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

១-ព្រះវិន័យធរ **មិន សាំងសេង** គង់នៅវត្តជ័យគីរី បច្ច័យចំនួន ១០១.២៣៧,៩៩ ដុល្លារ

២-លោក **ឆែម ចាន់ដារ៉ុង** សប្បុរសជននៅខេត្តកំពង់ចាម ថវិកាចំនួន ១០.៥០០ ដុល្លារ

៣-លោក **អ៊ុំ ស្រួស** សប្បុរសជននៅខេត្តកំពង់ចាម ថវិកាចំនួន ១០.១៩៦ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ✗+

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៤២៦...អន.ក្រ[illegible]

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៛ថ្ងៃ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូន ***ក្រុមហ៊ុនណាហ្គាខប*** (NAGA CORP) ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍន៍ កងយោធពលខេមរភូមិន្ទ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ... ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៣៣ អនុក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូន
-លោកវរសេនីយ៍ទោ **ម៉ៅ ចំរុង** អត្តលេខ ០១៤១០២ នាយការិយាល័យសេនាធិការទ្ធយោធា និងទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ៨ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...[illegible]...អនក្រ-បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរសក្តិ ជាកិច្ចបច្ចាមរណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យរបស់ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជាកិច្ចបច្ចាមរណៈ ជូនសព

១-វរសេនីយ៍ទោ **ទឹម ទុំឈ** អត្តលេខ ០០១៥១៣ នាយរងការិយាល័យផែនការ នាយកដ្ឋានប្រេងឥន្ធនៈ

២-វរសេនីយ៍ទោ **ស៊ុន សាឡុន** អត្តលេខ ០០៤១១៣ នាយសេនាធិការរង កងពលតូចអន្តរាគមន៍លេខ ១ អគ្គបញ្ជាការដ្ឋាន

៣-វរសេនីយ៍ទោ	**គីម សុផានណា** អត្តលេខ ០០៩៣៦៨	នាយការិយាល័យផ្តល់ពត៌មានយោធា បញ្ជាការដ្ឋានវេជ្ជសាស្ត្រ អគ្គបញ្ជាការដ្ឋាន
៤-វរសេនីយ៍ទោ	**សួន ទាន់ណាត** អត្តលេខ ០០២៦២០	មេបញ្ជាការរង កងរាជអាវុធហត្ថ ខេត្តកំពង់ធំ
៥-វរសេនីយ៍ទោ	**លឹម សំអឿន** អត្តលេខ ០០៤៩៣៧	នាយសេនាធិការរង កងពលធំអន្តរាគមន៍លេខ ២ អគ្គបញ្ជាការដ្ឋាន

មាត្រា២៖ រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៨ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតម្លើងថ្នាក់

មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្នុងឋានន្តរស័ក្តិវរមន្ត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតម្លើងថ្នាក់ លោក **សិន សុឃន** តាមកម្រិតសញ្ញាប័ត្រ ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៨ ទៅថ្នាក់លេខ ៧ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល :</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ - កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ៤៧០១ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " បណ្តុះវិជ្ជា "
ស្ថិតនៅក្នុង ឃុំ ស្វាយភ្លើង ស្រុក បារាយណ៍ ខេត្ត កំពង់ធំ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ ស្វាយភ្លើង ស្រុក បារាយណ៍ ចុះថ្ងៃទី ០៩ មិថុនា ២០០៦ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត កំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **បណ្តុះវិជ្ជា** " ស្ថិតនៅក្នុង ឃុំ ស្វាយភ្លើង ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ធំ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ. ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៦

ស្ពឺស្ទើរ កុល ផេង

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលា ខេត្ត កំពង់ធំ " ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ ឱ.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ២៣០៨ អយក.ប្រក

ប្រ កា ស

ស្ដីពីការបើកអនុវិទ្យាល័យ " ហ៊ុន សែន ទំរីង "

ស្ថិតនៅក្នុង ឃុំ ទំរីង ស្រុក សណ្ដាន់ ខេត្ត កំពង់ធំ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំណេះទូទៅ*១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្ដីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ ទំរីង ស្រុក សណ្ដាន់ ចុះថ្ងៃទី ២៥ ឧសភា ២០០៦ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត កំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ស ំ រ េ ច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " ហ៊ុន សែន ទំ រីង " ស្ថិតនៅក្នុង ឃុំ ទំរីង ស្រុក សណ្ដាន់ ខេត្ត កំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ធំ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៦

បណ្ឌិត កុល ផេង

កន្លែងទទួល:

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលា ខេត្ត កំពង់ធំ " ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ ទា.មចទ

fth Chetia/NewSchool.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ២៧០១ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " គំពង់ឫស្សី "

ស្ថិតនៅក្នុង ឃុំ ជីរោទិ៍១ ស្រុក ត្បូងឃ្មុំ ខេត្ត កំពង់ចាម

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ ជីរោទិ៍១ ស្រុក ត្បូងឃ្មុំ ចុះថ្ងៃទី ១១ សីហា ២០០៦ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត កំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " គំពង់ឫស្សី " ស្ថិតនៅក្នុង ឃុំ ជីរោទិ៍១ ស្រុក ត្បូងឃ្មុំ ខេត្ត កំពង់ចាម ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកជៀង១មួយចំនួនទៀតតាមអង្គភាពលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ចាម និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀង១ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ០៦ ... ឆ្នាំ២០០៦

បណ្ឌិត ក្រុល ផេង

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលា ខេត្ត កំពង់ចាម "ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ ន.មចទ

Ith Chetha/NewSchool doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ២៧៣០២ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " ស្រែអណ្តូង "

ស្ថិតនៅក្នុង ឃុំ សំឡូត ស្រុក សំឡូត ខេត្ត បាត់ដំបង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ សំឡូត ស្រុក សំឡូត ចុះថ្ងៃទី ០៨ កុម្ភៈ ២០០៦ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត បាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " ស្រែអណ្តូង " ស្ថិតនៅក្នុង ឃុំ សំឡូត ស្រុក សំឡូត ខេត្ត បាត់ដំបង ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមរង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត បាត់ដំបង និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ០៦ ... ឆ្នាំ២០០៦

បណ្ឌិត កុល ប៉េង

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលា ខេត្ត បាត់ដំបង " ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ ឯ.ចទទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

❋❋❋❋❋❋❋

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១៧៦៦ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " គិរីសិលាកែវ "

ស្ថិតនៅក្នុង ឃុំ តាក្រាម ស្រុក បាណន់ ខេត្ត បាត់ដំបង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ តាក្រាម ស្រុក បាណន់ ចុះថ្ងៃទី ៣០ ឧសភា ២០០៦ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត បាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **គិរីសិលាកែវ** " ស្ថិតនៅក្នុង ឃុំ តាក្រាម ស្រុក បាណន់ ខេត្ត បាត់ដំបង ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេង១មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត បាត់ដំបង និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀង១ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ ឆ្នាំ២០០៦

បណ្ឌិត កុល ផេង

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលា ខេត្ត បាត់ដំបង "ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ នា.មចទ

Ith Chetha/NewSchool.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ៥៣០ អយក.ប្រក

ប្រ កា ស

ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ " ភ្នំព្រឹក " ទៅជា វិទ្យាល័យ " ពេជ្រចិន្តា " ស្ថិតនៅក្នុង ឃុំ ពេជ្រចិន្តា ស្រុក ភ្នំព្រឹក ខេត្ត បាត់ដំបង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន្ន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៩២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ ពេជ្រចិន្តា ស្រុក ភ្នំព្រឹក ចុះថ្ងៃទី ២២ មីនា ២០០៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និងអភិបាល ខេត្ត បាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំ រេ ច

ប្រការ ១ : អនុញ្ញាតឱ្យពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ " **ភ្នំព្រឹក** " បច្ចុប្បន្ន ទៅជា វិទ្យាល័យ " **ពេជ្រចិន្តា** " ស្ថិតនៅក្នុង ឃុំ ពេជ្រចិន្តា ស្រុក ភ្នំព្រឹក ខេត្ត បាត់ដំបង ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត បាត់ដំបង នាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០០៦

បណ្ឌិត កឹម សេន

កន្លែងទទួល:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
"ដើម្បីជ្រាបជាពត៌មាន"
-សាលា ខេត្ត បាត់ដំបង "ដើម្បីជាពត៌មាន"
-ដូចប្រការ៥
-កាលប្បវត្តិ-ឯកសារ ន.មចទ

fth ChethaRe In School doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៦៣០៧ អយក.ប្រក

ប្រកាស

ស្តីពីការប្តូរឈ្មោះ វិទ្យាល័យ " សំរោងអណ្តែត " ទៅជា វិទ្យាល័យ " សម្តេច ហ៊ុន សែន ភ្នំពេញថ្មី " ស្ថិតនៅក្នុង សង្កាត់ ភ្នំពេញថ្មី ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៩២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ សង្កាត់ ភ្នំពេញថ្មី ខណ្ឌ ឫស្សីកែវ ចុះថ្ងៃទី ១១ កញ្ញា ២០០៦ ដោយមានយោបល់ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល រាជធានីភ្នំពេញ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យប្តូរឈ្មោះ វិទ្យាល័យ " សំរោងអណ្តែត " បច្ចុប្បន្ន ទៅជា វិទ្យាល័យ " សម្តេច ហ៊ុន សែន ភ្នំពេញថ្មី " ស្ថិតនៅក្នុង សង្កាត់ ភ្នំពេញថ្មី ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងនាយកវិទ្យាល័យ សាមីខានការកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ២០០៦

បណ្ឌិត គល់ ផេង

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជាបជាពតិមាន "
- សាលាក្រុងភ្នំពេញ "ដើម្បីជាពតិមាន"
- ដូចប្រការ៣
- កាលប្បវត្តិ-ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៥៩៩ ពណ.នតក

ភ្នំពេញថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: **អាហ្សាលីយ៉ា** **ASALIAH Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 3172/06 E ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា	: សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	: លោក HERVÉ, GAËTAN NICOLE
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ១៣៥ ក្រុមទី៩ ភូមិត្រពាំងសេះ ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប
៥- កម្មវត្ថុអាជីវកម្ម	: -សេវាកម្មលើការស្នាក់នៅជាលក្ខណៈទេសចរណ៍ក្នុងរយៈពេលខ្លី មធ្យម ឬវែង ដោយមានដាក់អោយប្រើប្រាស់នូវយានយន្តកង់ពីរ ឬកង់បួន (យានយន្តបើកបរលើផ្លូវគ្រប់ប្រភេទ) -ទិញ លក់ ផលិតផល ធ្វើជាអ្នកតំណាងលក់ នាំចូល-នាំចេញ និងចែកចាយ បោះដុំ ឬរាយ ដោយចល័ត ឬក្រោមទំរង់ផ្សេងទៀតនៃការលក់គ្រឿងឧបភោគ-បរិភោគ វត្ថុអនុស្សាវរីយ៍ សំភារៈប្រើប្រាស់ក្នុងផ្ទះ សំលៀកបំពាក់ វាយនភ័ណ្ឌ គ្រឿងអនាម័យ គ្រឿងដែក ព្រមទាំងផលិតផលសិប្បកម្មនិងឧស្សាហកម្មទាំងអស់ -ទិញ លក់ ជួល ដាក់ជួលគ្រប់ប្រភេទ ចូលរួមដោយផ្ទាល់ ឬដោយប្រយោលតាមគ្រប់មធ្យោបាយទាំងអស់ ឬក្រោមគ្រប់រូបភាព ទៅក្នុងសហគ្រាសនិងក្រុមហ៊ុនទាំងអស់ដែលបានបង្កើតឡើង ឬនឹងបង្កើតឡើង ដែលមានកម្មវត្ថុដូចគ្នា ឬប្រហាក់ប្រហែលគ្នា -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ -បើកសាលារៀន -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម -សេវារកការងារជូនអតិថិជនខ្មែរនិងជនបរទេស -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម
-ជាទូទៅ ធ្វើប្រតិបត្តិការឧស្សាហកម្ម ពាណិជ្ជកម្ម ហិរញ្ញវត្ថុ ចលនវត្ថុ ដែលអាចពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងកម្មវត្ថុអាជីវកម្មដូចបានរៀបរាប់ខាងលើ ឬពាក់ព័ន្ធទៅនឹងកម្មវត្ថុប្រហាក់ប្រហែល ឬទាក់ទងគ្នា ។

៦- ថិរវេលា : ៩៩ ឆ្នាំ

